# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីប្រចាំខែមិថុនា



លេខ ២៧២ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 272 Volume 23 Before Christ 2567 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ ........ ១
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២........ ២
- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភាដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ ........ ៤
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន២ ........ ៥
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........ ៨


## សកម្មភាពគណៈកម្មការ




- គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ រៀបចំពិធីអបអរសាទរខួបលើកទី៧៤ នៃទិវាកុមារអន្តរជាតិ ១មិថុនា ........ ៩
- គណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្តិ៍ច្រកកំពង់ផែអន្តរជាតិភ្នំពេញ ........ ១១
- គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ....... ១៣
- គណៈកម្មការទី១០ព្រឹទ្ធសភា នាំយកអំណោយសម្តេចប្រធានព្រឹទ្ធសភាប្រគល់ជូនរដ្ឋបាលខេត្តកណ្តាល ........ ១៥
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នាំយកអំណោយសម្តេចប្រធានព្រឹទ្ធសភាប្រគល់ជូនមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងខេត្តព្រៃវែង ........ ១៧
- សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យអាស៊ីអឺរ៉ុបចំនួន២០០នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា... ១៩
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........ ២១
- ការងារទទួលពាក្យបណ្តឹង........ ២៤
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨........ ២៥
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៤៤
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ........ ៤៧


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៣........ ៤៨
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញប្រគល់-ទទួលកញ្ចប់សម្ភារៈសិក្សាសម្រាប់ចែកជូនសិស្សានុសិស្សក្នុងខណ្ឌជ្រោយចង្វារ ........ ៥០
- ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលាស្តីពី ការតម្រង់ទិស និងផ្សព្វផ្សាយអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសចិន ........ ៥២
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ........ ៥៤



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម លឹម ប៊ុនហុក

ឯកឧត្តម កែវ ចាន់ណា

ឯកឧត្តម សុខ រិទ្ធី

ឯកឧត្តម គឹម ពិសិដ្ឋ

ឯកឧត្តម ជួន ណា

លោក ជួន សុខធី

លោក ទេព មករា

លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោកស្រី សុខ សុជាតា

លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទៅបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ នៅសាធារណរដ្ឋឥណ្ឌា។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**

**E-mail : oumsarith.sgsenate@gmail.com**

**Website: www.senate.gov.kh**

**www.elibrary.senate.gov.kh**

**Facebook: www.facebook.com/senateofcambodia**

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣



ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា　　សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ　　ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន

នាថ្ងៃចន្ទ ទី១២ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០ នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣រួមមាន៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន នៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

**២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ានទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

**៣-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃអង្គារ ទី១៣ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើ៖

**១-សេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ**

**២-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។**

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គឹម សិទ្ធី)



ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យហើយឱ្យយោបល់ លើសេចក្ដីព្រាងច្បាប់ចំនួន២




*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤*

យោងតាមស្មារតី នៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី ១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃអង្គារ ទី១៣ ខែមិថុនា ឆ្នាំ ២០២៣ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ រួមមាន៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ។**

ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាលើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិថា សេចក្ដីព្រាងក្រមនេះ តាក់តែងឡើងមានគោលបំណង ដើម្បីប្រមូលផ្ដុំសំយោគបញ្ចូលគ្នានូវបទប្បញ្ញត្តិ នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមានពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយធ្វើសមាហរណកម្ម សុខដុមនីយកម្ម និងទំនើបកម្មឱ្យមានភាពជាក់ស្ដែង-និយម សង្គតិភាព វិសាលភាព ទូលំទូលាយគ្រប់ជ្រុងជ្រោយ និងភាពស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា ដើម្បីក្លាយជាបទប្បញ្ញត្តិគោលដែលកំណត់ពីដែនសមត្ថកិច្ច នៃក្រសួង ស្ថាប័នពាក់ព័ន្ធសំដៅសម្រួលដល់ការអនុវត្តមុខងារ តួនាទី និងភារកិច្ចរៀងៗខ្លួន ក្នុងស្មារតីឯកភាពជាតិស្របទៅនឹងបរិបទរីកចម្រើន នៃសង្គមកម្ពុជាថ្មី។



*ឯកឧត្ដមបណ្ឌិត ម៉ុង ឫទ្ធី ឡើងអានរបាយការណ៍*



*ឯកឧត្ដម សាយ សំអាល់ ឡើងការពារសេចក្ដីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្ដម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។ អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។**

ឯកឧត្ដម **គង់ សារាជ** ប្រធានគណៈកម្មការទី៩



*ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍*

ព្រឹទ្ធសភា អញ្ជើញឡើងធ្វើសេចក្ដីរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ដែលរៀបចំឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

-ពង្រឹងការតភ្ជាប់សេដ្ឋកិច្ច និងការផ្ដល់កាលានុវត្តភាពកាន់តែប្រសើរឡើង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន។

-បង្កើនការធ្វើពាណិជ្ជកម្ម និងការវិនិយោគលើវិស័យពាណិជ្ជកម្មសេវាកម្ម ដោយបង្កើតទីផ្សារ និងសេដ្ឋកិច្ចកាន់តែទូលំទូលាយ។

-កាត់បន្ថយការរឹតត្បិតចំពោះពាណិជ្ជកម្មសេវាកម្ម និងបង្កើតបរិយាកាសពាណិជ្ជកម្មដែលអាចព្យាករណ៍បាន។

-ពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសជាសមាជិកទាំងអស់ តាមរយៈការលើកកម្ពស់ និងការសម្របសម្រួលដល់ការប្រើប្រាស់នូវកាលានុវត្តភាពកាន់តែប្រសើរ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងផ្នែកនិយ័តកម្ម ការបង្កើតកិច្ចសហប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើនការចូលរួមរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងសកម្មភាពពាណិជ្ជកម្មសេវាកម្ម។

-កាត់បន្ថយគម្លាត នៃការអភិវឌ្ឍរវាងប្រទេសសមាជិកអាស៊ាន ដើម្បីសម្រេចបាននូវសមភាព តុល្យភាព និងនិរន្តរភាព នៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។



*ឯកឧត្តម ប៉ាន សូរស័ក្តិ ឡើងការពារសេចក្តីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គង់ យ៉ារីន)



*សមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្តីព្រាងច្បាប់*

# សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភាដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣



*ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា* | *សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ* | *ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន*

នាថ្ងៃអង្គារ ទី២០ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣រួមមាន៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា អធិការកិច្ច និងមុខងារសាធារណៈ នៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី អគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤។**

**២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា សុំដាក់សេចក្ដីព្រាងច្បាប់ស្ដីពី វិធានដើមកំណើតទំនិញ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

**៣-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃពុធ ទី២១ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់លើ៖

**១-សេចក្ដីព្រាងច្បាប់ស្ដីពី អគ្រានុកូលដ្ឋាន ស្ថិតិអគ្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។**

**២-សេចក្ដីព្រាងច្បាប់ស្ដីពី វិធានដើមកំណើតទំនិញ៕**

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គឹម សិទ្ធី)





*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យហើយឱ្យយោបល់ លើសេចក្តីព្រាងច្បាប់ចំនួន២




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤*

យោងតាមស្មារតី នៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃពុធ ទី២១ ខែមិថុនា ឆ្នាំ២០២៣ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ រួមមាន៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និង អត្តសញ្ញាណកម្ម។**

ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំជ្រាបអំពី លទ្ធផល នៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ថា សេចក្តីព្រាងច្បាប់នេះ មានគោលបំណងសំខាន់គឺ ធានាឱ្យមានវិធាន និងនីតិវិធីច្បាស់លាស់ទាក់ទងទៅនឹងការ ចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គល ការចុះបញ្ជីស្នាក់នៅ ដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចការពារ សិទ្ធិ និងការលើកកម្ពស់គុណភាព នៃការផ្តល់សេវាគ្រប់ ប្រភេទជូនប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ ព្រមទាំង ធានាឱ្យបុគ្គលគ្រប់រូបមានអត្តសញ្ញាណតាមផ្លូវច្បាប់ និង ជាមូលដ្ឋានសម្រាប់ការរៀបចំគ្រប់គ្រងស្ថិតិអត្រានុកូលដ្ឋាន និងបញ្ជីប្រជាជន ព្រមទាំងរៀបចំផែនការសម្រាប់ អភិវឌ្ឍន៍ផងដែរ។

សេចក្តីព្រាងច្បាប់នេះ គឺជាសមិទ្ធផលថ្មីមួយបន្ថែមទៀត ដែលរៀបចំឡើងមិនត្រឹមតែអាចឆ្លើយតបក្នុងការដោះ-



*ឯកឧត្តម សុខ ឥសាន ឡើងអានរបាយការណ៍*

ស្រាយបញ្ហាដែលបានជួបប្រទះក្នុងពេលអនុវត្តជាក់ស្តែងកន្លងមកប៉ុណ្ណោះនោះទេ គឺជានាបាននូវតម្លាភាពក្នុងការផ្តល់សេវា និងបានរៀបចំបទប្បញ្ញត្តិដែលមានលក្ខណៈទំនើបកម្មស្របតាមការរីកចម្រើននៅក្នុងសង្គម ព្រមទាំងបានរៀបចំដោយព្យាករណ៍ទុកជាមុនរួចស្រេចទាក់ទងនឹងការបន្តរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថលនាថ្ងៃអនាគតផងដែរ។



*សម្តេចក្រឡាហោម ស ខេង ឡើងការពារសេចក្តីព្រាងច្បាប់*

ក្រោយពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិធានដើមកំណើតទំនិញ។**

ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា អញ្ជើញឡើងធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំជ្រាបអំពីលទ្ធផល នៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ដែលរៀបចំឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

-កំណត់គោលការណ៍ នៃវិធានដើមកំណើតទំនិញក្រោម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដើម្បីបំពេញបានតាមការសន្យារបស់កម្ពុជា ជាមួយនឹងអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងដោយអនុលោមជាមួយនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិនានា។

-ដើម្បីជំរុញ និងសម្រួលពាណិជ្ជកម្ម និងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ ជាពិសេសដើមកំណើតទំនិញកម្ពុជា។

សេចក្តីព្រាងច្បាប់នេះ គឺជាឧបករណ៍គតិយុត្តដែលមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ដែលជាចំណែកមួយដ៏សំខាន់ក្នុងការ៖

-កំណត់អំពីគោលការណ៍ និងវិធានដើមកំណើតទំនិញទាំងវិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ដែលបច្ចុប្បន្នកម្ពុជាពុំទាន់មានច្បាប់ចែងដោយឡែកអំពី វិធានដើមកំណើតទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធនៅឡើយទេ។ ក្រៅពីការអនុវត្តផ្នែកនេះតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ដែលកម្ពុជាជាសមាជិក។

-ផ្តល់ជាមូលដ្ឋានច្បាប់ច្បាស់លាស់ដល់អាជ្ញាធរមាន



*ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍*

សមត្ថកិច្ច ជាពិសេសក្រសួងពាណិជ្ជកម្ម ដែលទទួលបន្ទុកចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ជាសេនាធិការទទួលបន្ទុកលើការទទួលសំអាងដើមកំណើតទំនិញ ក្នុងការអនុវត្តការងារទាក់ទងនឹងវិធានដើមកំណើតទំនិញ។

-ជួយឱ្យកម្ពុជាអាចបំពេញបាននូវការសន្យារបស់ខ្លួនក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក។

-ជួយជំរុញ និងសម្រួលពាណិជ្ជកម្មដល់វិស័យឯកជនជាពិសេសការនាំចេញទំនិញរបស់កម្ពុជា ដែលទទួលបានការអនុគ្រោះពន្ធពីប្រទេសនាំចូល ដែលផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មដល់កម្ពុជា និងក្រោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាដែលកម្ពុជាជាសមាជិក។

-ចូលរួមបង្ការ និងទប់ស្កាត់ការក្លែងបន្លំដើមកំណើតទំនិញ ដែលអាចជួយធានាថា ទំនិញនាំចេញពីកម្ពុជា គឺមានដើមកំណើតនៅកម្ពុជា ហើយអនុលោមតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាដែលកម្ពុជាជាសមាជិក និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

-តាមរយៈយន្តការនានាក្នុងច្បាប់នេះនឹងជួយឱ្យកម្ពុជារក្សាបាននូវផលប្រយោជន៍សេដ្ឋកិច្ច ដែលទទួលបានពីប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាដែលកម្ពុជាជាសមាជិក រួមទាំងអាចជួយកៀរគរចំណូលថវិកាជាតិ។



*ឯកឧត្តម ប៉ាន សូរស័ក្តិ ឡើងការពារច្បាប់*

បន្ទាប់ពីសមាជិកព្រឹទ្ធសភាបានឡើងមានយោបល់រួចមក ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៦០សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គង់ យ៉ារីន)





*សមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្តីព្រាងច្បាប់*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដង្ហែព្រះរាជដំណើរព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គស្ដេចយាងទៅបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ រយៈពេល៣ថ្ងៃ នៅសាធារណរដ្ឋឥណ្ឌា។



❈នារសៀលថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទទួលព្រះរាជដំណើរយាងនិវត្តន៍របស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គស្ដេចយាងមកកាន់មាតុប្រទេសវិញ បន្ទាប់ពីបំពេញព្រះរាជទស្សនកិច្ចផ្លូវរដ្ឋ រយៈពេល៣ថ្ងៃ នៅសាធារណរដ្ឋឥណ្ឌា។



❈នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងបាវិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។



# គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ រៀបចំពិធីអបអរសាទរខួបលើកទី៧៤ នៃទិវាកុមារអន្តរជាតិ ១មិថុនា



*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ រៀបចំពិធីអបអរសាទរខួបលើកទី៧៤ នៃទិវាកុមារអន្តរជាតិ ១មិថុនា*

គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានរៀបចំពិធីអបអរសាទរខួបលើកទី៧៤ នៃទិវាកុមារអន្តរជាតិ ១មិថុនា និងផ្សព្វផ្សាយព្រះរាជសារព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាឱទ្បារិកជូនជនរួមជាតិ អ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់ អញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខ។

ក្នុងឱកាសអបអរសាទរខួបលើកទី៧៤ នៃទិវាកុមារអន្តរជាតិ ១មិថុនា នៅព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្ដឹង និងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ សហការជាមួយនឹងអាជ្ញាធរខេត្តមណ្ឌលគិរី បានរៀបចំប្រារព្ធពិធីអបអរសាទរទិវាកុមារអន្តរជាតិនៅសាលាបឋមសិក្សាពូឡា ស្ថិតនៅភូមិពូហ្យាម ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ក្រោមអធិបតីភាពឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ថង សាវុន** អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី ថ្នាក់ដឹកនាំខេត្ត សប្បុរសជនដែលឧបត្ថម្ភសម្ភារៈសិក្សាដល់សិស្សានុសិស្ស មន្ទីរពាក់ព័ន្ធជុំវិញខេត្ត លោកគ្រូ អ្នកគ្រូ មាតា បិតា អាណាព្យាបាលសិស្ស និងសិស្សានុសិស្សមកពីសាលាបឋមសិក្សាពូឡា និងសាលាបឋមសិក្សាចុងរ៉ាំង សរុបចំនួន៣៥០ នាក់។



*ឯកឧត្តម យ៉ង់ សែម អញ្ជើញសំណេះសំណាលក្នុងអង្គពិធី*

ក្នុងឱកាសដ៏មហោទ្បារិកនោះ ឯកឧត្តម **យ៉ង់ សែម** បានពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ភូមិ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស បងប្អូន កូនក្មួយជាមាតាបិតាអាណាព្យាបាលសិស្សទាំងអស់។ ឯកឧត្តមបានរំលឹកអំពីប្រវត្តិ នៃទិវាកុមារអន្តរជាតិ និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល



*ទិដ្ឋភាពអ្នកចូលរួមក្នុងអង្គពិធី*

ក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការថែទាំ គាំពារ និងលើកកម្ពស់សិទ្ធិកុមារ។

នៅក្នុងពិធីនោះដែរ ឯកឧត្ដម **យ៉ង់ សែម** បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋសូមអញ្ជើញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខឱ្យបានគ្រប់ៗគ្នា ដើម្បីជ្រើសរើសអ្នកដឹកនាំប្រទេសជាតិ ដើម្បីការអភិវឌ្ឍ និងការរីកចម្រើនរុងរឿងថ្កើងថ្កានលើគ្រប់វិស័យ។ នៅចុងបញ្ចប់ នៃពិធី មានចែកអំណោយជាសម្ភារៈសិក្សា ថវិកាដល់សិស្សានុសិស្ស និងព្រះរាជសារព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋធម្មនុញ្ញ ព្រមទាំងជូនថវិកាដល់សាលាបឋមសិក្សាពូឡា សាលាបឋមសិក្សាចុងរ៉ាង លោកគ្រូ អ្នកគ្រូ ក្រុមប្រឹក្សាឃុំ នគរបាលប៉ុស្តិ៍ប្រជាការពារ និងប្រជាពលរដ្ឋដែលជាមាតា បិតាសិស្សផងដែរ៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ចែកសម្ភារៈសិក្សាដល់សិស្សានុសិស្ស*



*គណៈកម្មការទី១ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរខេត្តមណ្ឌលគិរី*

# គណៈកម្មការទី៥ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្ដិ៍ច្រកកំពង់ផែអន្ដរជាតិភ្នំពេញ





*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្ដិ៍ច្រកកំពង់ផែអន្ដរជាតិភ្នំពេញ*

ដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីវិស័យជាសមត្ថកិច្ចរបស់ខ្លួន នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្ដរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ប៉ូរ៉ាស៊ី** ប្រធានគណៈកម្មការ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយនឹងនគរបាលប៉ុស្ដិ៍ច្រកកំពង់ផែអន្ដរជាតិភ្នំពេញ ស្ថិតក្នុងភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

ក្នុងឱកាសនោះ លោកវរសេនីយ៍ឯក **ឈួន សុវណ្ណនរា** នាយប៉ុស្ដិ៍នគរបាលច្រកទ្វារកំពង់ផែអន្ដរជាតិភ្នំពេញ បានធ្វើសេចក្ដីរាយការណ៍ជូនគណៈប្រតិភូជ្រាបថា ប៉ុស្ដិ៍នគរបាលច្រកកំពង់ផែអន្ដរជាតិភ្នំពេញ មានគោលដៅប្រតិបត្តិការចំនួន៤កន្លែង គឺចំណតផែពហុបំណង TS3 ចំណតផែកុងតឺន័រ LM17 ចំណុចកណ្ដុធារ និងចំណតផែរណបពហុបំណង។ ដោយឡែកការដឹកជញ្ជូនទំនិញ នាវាដឹកទំនិញត្រូវបានបែងចែកជា២គឺ៖ **១**-នាវាដឹកកុងតឺន័រ និង**២**-នាវាដឹកទំនិញរាយ។ ចំពោះនាវាទេសចរណ៍ដែលចូលមកកំពង់ផែស្វយ័តភ្នំពេញ គឺមកពីប្រទេសវៀតណាម ដែលឆ្លងកាត់តាមមាត់ច្រកចំនួន២គឺ៖មាត់ច្រកក្អមសំណ និងមាត់ច្រកកោះរកា មានភ្ញៀវទេសចរចម្រុះជាតិសាសន៍ដែលភាគច្រើនគឺ៖ អាមេរិក អង់គ្លេស កាណាដា បារាំង និងអូស្ត្រាលី។



*លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ទី ប៉ូរ៉ាស៊ី ប្រគល់វត្ថុអនុស្សាវរីយ៍ជូនឈួន សុវណ្ណនរា នាយប៉ុស្ដិ៍នគរបាលច្រកទ្វារកំពង់ផែអន្ដរជាតិភ្នំពេញ*



*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយនគរបាលច្រកទ្វារកំពង់ផែអន្ដរជាតិភ្នំពេញ*

ក្នុងនាមគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម្ញ៉ាស៊ី** បានពាំនាំនូវការសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះនគរបាលច្រកទ្វារកំពង់ផែអន្តរជាតិភ្នំពេញ។ ជាមួយគ្នានោះ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត បានជម្រាបអំពីគោលបំណង នៃជំនួបពិភាក្សានាឱកាសនោះ ដើម្បីបង្កើនទំនាក់ទំនងជិតស្និទ្ធរវាងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា ជាមួយនឹងនគរបាលប៉ុស្តិ៍ច្រកកំពង់ផែអន្តរជាតិភ្នំពេញ ព្រមទាំងឈ្វេងយល់អំពីសកម្មភាពភ្ញៀវចេញ-ចូល ការដឹកជញ្ជូនទំនិញចេញ-ចូល នៅច្រកកំពង់ផែអន្តរជាតិភ្នំពេញ ជាពិសេសការអនុវត្តច្បាប់អន្តោប្រវេសន៍។

តាមរយៈសេចក្តីរាយការណ៍របស់នាយប៉ុស្តិ៍នគរបាលច្រកកំពង់ផែអន្តរជាតិភ្នំពេញរួចមក លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម្ញ៉ាស៊ី** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមចែករំលែកព័ត៌មាន និងធ្វើសេចក្តីរាយការណ៍យ៉ាងក្បោះក្បាយ។ តាមរយៈសេចក្តីរាយការណ៍នោះដែរ បានឆ្លុះបញ្ចាំងឱ្យឃើញអំពីការខិតខំប្រឹងប្រែងក្នុងការបំពេញការងាររបស់នគរបាលប៉ុស្តិ៍ជាពិសេសការអនុវត្តច្បាប់អន្តោប្រវេសន៍នៅតំបន់ដែលខ្លួនគ្រប់គ្រង។ ទន្ទឹមនឹងនោះដែរ ក្នុងនាមគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសលបណ្ឌិត ប្រធានគណៈកម្មការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកនាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ ដែលបានឆ្លៀតឱកាសដ៏មមាញឹក មកជួប និងផ្តល់ព័ត៌មានជូនដល់គណៈកម្មការទី៥ព្រឹទ្ធសភា ព្រមទាំងបានបង្ហាញអំពីការអនុវត្តតួនាទី ភារកិច្ច ការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងការគ្រប់គ្រងការដឹកជញ្ជូនទំនិញចេញ-ចូល និងសកម្មភាពចេញ-ចូលរបស់ជនបរទេស នៅច្រកកំពង់ផែអន្តរជាតិភ្នំពេញ ដោយទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ។

លោកជំទាវកិត្តិនីតិកោសលបណ្ឌិត បានជំរុញឱ្យនគរបាលប៉ុស្តិ៍ច្រកកំពង់ផែអន្តរជាតិភ្នំពេញ នាយកប្រតិបត្តិការចំណតផែទាំងអស់បន្ត និងពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការងារគ្រប់គ្រងកំពង់ផែអន្តរជាតិភ្នំពេញកាន់តែប្រសើរថែមទៀត៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)



គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញទស្សនៈកិច្ច នៅច្រកកំពង់ផែអន្តរជាតិភ្នំពេញ



គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយនគរបាលចាំប៉ុស្តិ៍ច្រកកំពង់ផែអន្តរជាតិភ្នំពេញ

# គណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្តិ៍ ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ





*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយនគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ*

ដោយផ្អែកលើមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដើម្បីឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅអំពីវិស័យជាសមត្ថកិច្ចរបស់ខ្លួន នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា(គណៈកម្មការទី៥) ដឹកនាំដោយលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការ បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយនឹងនគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដឹកនាំដោយលោកឧត្តមសេនីយ៍ត្រី **ឈូ គឹមនី** នាយប៉ុស្តិ៍នគរបាលច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ត្រី **ឈូ គឹមនី** នាយប៉ុស្តិ៍នគរបាលច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានធ្វើសេចក្តីរាយការណ៍ជូនគណៈប្រតិភូជ្រាបថា ការអនុវត្តច្បាប់អន្តោប្រវេសន៍នៅតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺប្រព្រឹត្តទៅបានដោយរលូន ដោយនគរបាលប៉ុស្តិ៍បានអនុវត្តទាន់ពេលវេលា ទៅតាមអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងអនុក្រឹត្យ១២៣ ស្តីពីបែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន៍ចូល-ចេញ និងស្នាក់អាស្រ័យនៅប្រទេសកម្ពុជា។

លោកឧត្តមសេនីយ៍ត្រីបានបញ្ជាក់ថា គិតចាប់ពីថ្ងៃទី១ ខែមករា រហូតមកដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣



អាជ្ញាធរអន្តោប្រវេសន៍ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ធ្វើការបង្ក្រាបបានបទល្មើសដូចជា៖គ្រឿងញៀន និងការជួញដូរមនុស្ស។ល។ ដោយសរុបមានចំនួន១.០២៥នាក់ (ស្ត្រីមាន១៦៩នាក់) ហើយមាន៣០សញ្ជាតិ។ ក្នុងឆ្នាំ២០២៣ ជនល្មើសដែលត្រូវបណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជាមានសរុបចំនួន៤២០នាក់ (ស្ត្រី៤៧នាក់) រួមមាន៖ ជនជាតិចិន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ចិនតៃវ៉ាន់ និងជនជាតិឥណ្ឌា។

ក្នុងនាមគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ឌី ម៉ូរ៉ាស៊ី** បានពាំនាំនូវការសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភាជូនចំពោះនគរបាលច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ជាមួយគ្នានោះ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត បានជម្រាបអំពីគោលបំណង នៃជំនួបពិភាក្សាគឺ ដើម្បីបង្កើនទំនាក់ទំនងជិតស្និទ្ធរវាងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃព្រឹទ្ធសភា ជាមួយនឹងប៉ុស្តិ៍នគរបាលច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ព្រមទាំងឈ្វេងយល់អំពីសកម្មភាពភ្ញៀវចេញ-ចូល និងការអនុវត្តច្បាប់អន្តោប្រវេសន៍។

ជាមួយគ្នានោះ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត បានថ្លែងអំណរគុណចំពោះនគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលបានទទួលស្វាគមន៍គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភា ព្រមទាំងបានធ្វើសេចក្ដីរាយការណ៍យ៉ាងក្បោះក្បាយ ហើយតាមរយៈសេចក្ដីរាយការណ៍គឺបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការខិតខំប្រឹងប្រែងក្នុងការបំពេញការងាររបស់នគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជាពិសេសការអនុវត្តច្បាប់អន្តោប្រវេសន៍ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្ត នៅតំបន់ដែលខ្លួនគ្រប់គ្រង និងការអនុវត្តបានទាន់ពេលវេលាចំពោះអនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងអនុសាសន៍របស់សម្ដេចបានល្អប្រសើរ ជាពិសេសការទប់ស្កាត់បានទាន់ពេលវេលាចំពោះរាល់បទល្មើសនានាផងដែរ។

ជាមួយនឹងលទ្ធផលវិជ្ជមានដែលទទួលបានទាំងនេះ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ឌី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានជំរុញឱ្យនគរបាលប៉ុស្តិ៍ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ព្រមទាំងអាជ្ញាធរពាក់ព័ន្ធទាំងអស់បន្តសហការគ្នាពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីធានាដល់ការអនុវត្តតួនាទី ភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ឱ្យបានកាន់តែមានប្រសិទ្ធភាពថែមទៀត៕

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)







*គណៈប្រតិភូគណៈកម្មការទី៥ព្រឹទ្ធសភាអញ្ជើញទស្សនៈកិច្ច
នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ*

# គណៈកម្មការទី១០ព្រឹទ្ធសភា នាំយកអំណោយសម្ដេចប្រធានព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តកណ្ដាល





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភាជួបសំណេះសំណាលជាមួយអាជ្ញាធរខេត្តកណ្ដាល*

អំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ រួមមាន៖ ឱសថ បរិក្ខារពេទ្យ សម្ភារប្រើប្រាស់ប្រចាំថ្ងៃ សម្ភារសម្រាប់ក្មេងលេង និងសៀវភៅសរសេរសរុបជាថវិកាប្រមាណជាង៥៩ ម៉ឺនដុល្លារអាមេរិក ត្រូវបានគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ អ្នកនាំពាក្យព្រឹទ្ធសភា និងជាតំណាងដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា យកទៅប្រគល់ជូនរដ្ឋបាលខេត្តកណ្ដាល នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ នៅសាលាខេត្តកណ្ដាល។

ក្នុងឱកាសដ៏ថ្លៃថ្លានោះ ឯកឧត្ដម **គង់ សោភ័ណ្ឌ** អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល បានមានប្រសាសន៍ថ្លែងអំណរគុណ ជូនចំពោះសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ដែលតែងតែយកចិត្តទុកដាក់ចំពោះសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋនៅទូទាំងប្រទេស ក៏ដូចជាបងប្អូនប្រជាពលរដ្ឋនៅខេត្តកណ្ដាល។ តាមរយៈការផ្ដល់ជំនួយនាឱកាសនោះ អាជ្ញាធរខេត្តកណ្ដាលនឹងធ្វើការបែងចែកឱ្យបានទៅដល់ថ្នាក់មូលដ្ឋាន ឱ្យចំគោលដៅ ស្របតាមសេចក្ដីប្រាថ្នារបស់សម្ដេចប្រធានព្រឹទ្ធសភា






*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ប្រគល់អំណោយរបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនអាជ្ញាធរខេត្តកណ្តាល*

និងលោកជំទាវ។

ជាមួយគ្នានោះ ឯកឧត្តម **ម៉ម ម៉ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានបញ្ជាក់ថា អំណោយដ៏ថ្លៃថ្លារបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ បានមកពីការរួមចំណែករបស់មូលនិធិចែករំលែកសង្គ្រោះជីវិតសាកលនៃសាធារណរដ្ឋកូរ៉េ។ អំណោយដ៏ថ្លៃថ្លាទាំងនេះ គឺជាការចូលរួមចំណែកចំពោះការលើកកម្ពស់ជីវភាពរបស់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាការចូលរួមចំណែកចំពោះការលើកកម្ពស់ការងារសុខាភិបាលរបស់អាជ្ញាធរមូលដ្ឋាន។ ដូចនេះសូមអាជ្ញាធរខេត្តធ្វើយ៉ាងណាខិតខំបែងចែកអំណោយឱ្យបានទៅដល់ថ្នាក់មូលដ្ឋាន ជាពិសេសចំនឹងតម្រូវការរបស់បងប្អូនប្រជាពលរដ្ឋនៅខេត្តកណ្តាល។ ទន្ទឹមនឹងនោះត្រូវសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីទទួលបាននូវព័ត៌មានអំពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីរួមចំណែកដោះស្រាយការខ្វះខាតរបស់ប្រជាពលរដ្ឋឱ្យទាន់ពេលវេលា៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ រូបភាព៖ គង់ យ៉ារីន)





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភាអញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរខេត្តកណ្តាល*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នាំយកអំណោយសម្ដេចប្រធានព្រឹទ្ធសភាប្រគល់ជូនមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពក្នុងខេត្តព្រៃវែង




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នាំអំណោយរបស់សម្ដេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនមន្ទីរពេទ្យបង្អែកស៊ីធរកណ្ដាល ខេត្តព្រៃវែង*

នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមភាគទី៦ ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បាននាំយកអំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ រួមមាន៖ ឱសថ សរុបចំនួន៤៩កេស និងតេស្តរហ័សកូវីដ-១៩ចំនួន ១កេសធំ និង១០ប្រអប់តូច ទៅប្រគល់ជូនមន្ទីរពេទ្យបង្អែកស៊ីធរកណ្ដាល មន្ទីរពេទ្យបង្អែកស្វាយអន្ទរ មណ្ឌលសុខភាពព្រៃទឹង មណ្ឌលសុខភាពព្រៃដើមថ្នឹង និងមណ្ឌលសុខភាពអំពិលក្រៅ នៅខេត្តព្រៃវែង។

ក្នុងឱកាសនោះ លោកជំទាវ **មាន សំអាន** បានពាំនាំនូវការសួរសុខទុក្ខពីសំណាក់សម្ដេចប្រធានព្រឹទ្ធសភា ដែលតែងតែយកចិត្តទុកដាក់ជានិច្ចចំពោះសុខទុក្ខ និងការលំបាក ជាពិសេសបញ្ហាសុខភាពរបស់បងប្អូនប្រជា-ពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ពីព្រោះថាសុខភាពគឺជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចខ្វះបាន ហើយសុខភាពគឺជាកត្តាចម្បងសម្រាប់លើកកម្ពស់ជីវភាពគ្រួសារ។

លោកជំទាវ **មាន សំអាន** សង្ឃឹមថា អំណោយទាំង-




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នាំអំណោយរបស់សម្ដេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនមណ្ឌលសុខភាពព្រៃទឹង ខេត្តព្រៃវែង*




*លោកជំទាវ មាន សំអាន ជួបសំណេះសំណាលជាមួយក្រុមគ្រូពេទ្យ និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ នៅមណ្ឌលសុខភាពព្រៃដើមថ្នឹង ខេត្តព្រៃវែង*



*លោកជំទាវ មាន សំអាន ថតរូបអនុស្សាវរីយ៍ជាមួយក្រុមគ្រូពេទ្យ នៅមណ្ឌលសុខភាពព្រៃដើមថ្នឹង*

អស់នេះ នឹងចូលរួមចំណែកចំពោះការលើកកម្ពស់សុខុ-មាលភាពរបស់បងប្អូនប្រជាពលរដ្ឋ ក៏ដូចជាការចូលរួមចំណែកចំពោះការលើកកម្ពស់ការងារសុខាភិបាលរបស់អាជ្ញាធរមូលដ្ឋាន។ ជាមួយគ្នានោះ លោកជំទាវបានបញ្ជាក់ថា អំណោយដ៏ថ្លៃថ្លារបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ បានមកពីការរួមចំណែករបស់មូលនិធិចែក-រំលែកសង្គ្រោះជីវិតសាកល នៃសាធារណរដ្ឋកូរ៉េ។ មូលនិធិចែករំលែកសង្គ្រោះជីវិតសាកល នៃសាធារណរដ្ឋកូរ៉េ គឺជាដៃគូសហប្រតិបត្តិការជាមួយនឹងព្រឹទ្ធសភា ដែលបានផ្តល់ជាជំនួយមនុស្សធម៌យ៉ាងច្រើនជូនដល់ព្រឹទ្ធសភា។ កាលពីពេលកន្លងទៅ ព្រឹទ្ធសភាក៏បាននាំយកអំណោយទាំងអស់នោះទៅប្រគល់ជូនក្រសួង ស្ថាប័ន និងអាជ្ញាធរនៅតាមបណ្តាខេត្តមួយចំនួនផងដែរ។

(អត្ថបទ និងរូបភាព៖ គឹម សិទ្ធី)




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នាំអំណោយរបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនមណ្ឌលសុខភាពអំពិលក្រៅ ខេត្តព្រៃវែង*

# សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យអាស៊ីអឺរ៉ុបចំនួន២០០នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា




*លោកជំទាវ សួន ពុធថាវី ឯកឧត្តម ម៉ែន ស៊ីផាន់ និងលោកស្រី ឃុន សុវណ្ណនេត្រា*

នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យអាស៊ីអឺរ៉ុបចំនួន២០០នាក់ បានអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យអាស៊ីអឺរ៉ុប បានអញ្ជើញស្ដាប់បទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ដោយឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា។ បទបង្ហាញស្ដីពី ដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា ដោយលោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងបទបង្ហាញស្ដីពី រចនាសម្ព័ន តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយលោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **ម៉ែន-ស៊ីផាន់** បានជម្រាបជូនអំពីប្រវត្តិរបស់ព្រឹទ្ធសភា តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ភាពខុសគ្នារវាងព្រឹទ្ធសភា និងរដ្ឋសភា តួនាទី និងភារកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភានៅតាមមណ្ឌលភូមិភាគ និងការបង្កើតព្រឹទ្ធសភាឡើង ដើម្បីជាប្រវត្តិសាស្ត្រ បញ្ចប់វិបត្តិនយោបាយ លើកកម្ពស់ការបង្រួបបង្រួមផ្សះផ្សាជាតិ ពង្រឹងស្ថិរភាពនយោបាយ និងបង្ហាញឱ្យឃើញពីការប្ដេជ្ញាចិត្តក្នុងការកសាងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋដូចអារ្យប្រទេសនានា។ សមាជិកព្រឹទ្ធសភាមានចំនួនយ៉ាងច្រើនស្មើនឹងពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំង ដោយការបោះឆ្នោតអសកល និងមិនចំពោះ (កើតចេញពីអង្គបោះឆ្នោតដែលបានជ្រើសរើសចេញពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់) សមាជិក២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិក២រូបត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។

ឯកឧត្តមបានបញ្ជាក់ថា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាមាន៖ ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការទាំង១០របស់ព្រឹទ្ធសភា។ ព្រឹទ្ធសភាកម្ពុជាប្រកាន់យកមុខងារសំខាន់បី មាន៖ ១.មុខងារតំណាង គឺពិនិត្យហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ(មាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ)។ ២.មុខងារត្រួតពិនិត្យ គឺគណៈកម្មការជំនាញរបស់ព្រឹទ្ធសភា



*ឯកឧត្តម ម៉ែន ស៊ីផាន់ អញ្ជើញធ្វើបទបង្ហាញ*



*ទិដ្ឋភាពសាស្ត្រាចារ្យ និងនិស្សិតនៃសកលវិទ្យាល័យអាស៊ីអឺរ៉ុបក្នុងពិធីធ្វើបទបង្ហាញ*

(គណៈកម្មការទាំង១០ព្រឹទ្ធសភា) ជាសេនាធិការត្រូវអនុវត្តមុខងារដូចជា៖ ការតាមដាន និងត្រួតពិនិត្យការផ្សព្វផ្សាយច្បាប់ ការអនុវត្តច្បាប់ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងការអនុវត្តសកម្មភាពនានារបស់បណ្ដាក្រសួងជំនាញ។ **៣**.មុខងារតំណាង គឺតំណាងឱ្យផលប្រយោជន៍ នៃក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមមណ្ឌលភូមិភាគនីមួយៗ(មាត្រា ១១ នៃច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា)។ ក្រៅពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួនពីរទៀត គឺមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារការអភិវឌ្ឍស្ថាប័ន។

បន្ទាប់ពីស្ដាប់បទបង្ហាញទាំងបីខាងលើរួចមក សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យអាស៊ីអឺរ៉ុប បានអញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា បណ្ណាល័យព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានានៅក្នុងបរិវេណព្រឹទ្ធសភា។ សូមរំលឹកផងដែរថា៖ វិមានព្រឹទ្ធសភា អតីតវិមានរដ្ឋចំការមន ដែលត្រូវបានផ្ដួចផ្ដើមគំនិតកសាងឡើងក្នុងទសវត្សរ៍ទី៥០ ដោយព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ។ វិមានរដ្ឋចំការមន គឺជាទីកន្លែងសម្រាប់ទទួលបដិសណ្ឋារកិច្ចប្រមុខរដ្ឋ នៃប្រទេសនានា ជាកន្លែងធ្វើការងារ និងជាព្រះរាជដំណាក់របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះរាជដំណាក់របស់ព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងព្រះរាជដំណាក់របស់ព្រះរាជបុត្រី **នរោត្តម បុប្ផាទេវី**។ ក្រៅពីនេះ នៅក្នុងវិមានរដ្ឋចំការមន ក៏មានសាលបដិសណ្ឋារកិច្ច សាលរៀបចំពិធីជប់លៀង អគារការិយាល័យ កន្លែងស្នាក់នៅរបស់ភ្ញៀវ និងរោងភាពយន្តផងដែរ។ បច្ចុប្បន្នវិមានរដ្ឋចំការមន គឺជាកន្លែងធ្វើការរបស់ស្ថាប័នកំពូលៗចំនួន៣ គឺព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលមានអាសយដ្ឋាននៅតាមបណ្ដោយមហាវិថីព្រះនរោត្តម ជាប់វិមាន៧មករា (គណបក្សប្រជាជនកម្ពុជា)៕

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)





*ទិដ្ឋភាពសាស្ត្រាចារ្យ និងនិស្សិតនៃសកលវិទ្យាល័យអាស៊ីអឺរ៉ុប*
*អញ្ជើញទស្សនាសាលប្រជុំព្រឹទ្ធសភា*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា



❋នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ខា ខេឌ្ឍ** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំជាមួយនឹងការិយាល័យអមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ និងលេខាធិការដ្ឋានអមគណៈកម្មការទី២ព្រឹទ្ធសភា ស្ដីពីការតាមដានការងារក្រោយវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ដែលប្រព្រឹត្តទៅកាលពីថ្ងៃទី៣១ ខែមករា និងថ្ងៃទី២ ខែមីនា ឆ្នាំ២០២៣កន្លងទៅ នៅសាលប្រជុំគណៈកម្មការទី២ព្រឹទ្ធសភា។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី៣ព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ។

-នារសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈកម្មការព្រឹទ្ធសភាជួបជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន



ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ នៅវិមានព្រឹទ្ធសភា។

❋ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី៤ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បីពិនិត្យ ពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន២ និងត្រៀមឡើងមានយោបល់ នៅក្នុងសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។



-នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្ម-

ការទី៤ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណ-កម្ម។



-នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈកម្ម-ការជួបជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញា-ណកម្ម នៅវិមានព្រឹទ្ធសភា។



-នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្ម-ការទី៤ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បី ពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន២ និងត្រៀម ឡើងមានយោបល់ នៅក្នុងសម័យប្រជុំលើកទី១០ ព្រឹទ្ធ-សភានីតិកាលទី៤។

❋លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី បូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ ដូចខាងក្រោម៖

-នាព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ នៅគណៈកម្ម-ការទី៥ព្រឹទ្ធសភា ដើម្បីត្រៀម៖

១-ពិនិត្យរបាយការណ៍សកម្មភាពការងាររបស់គណៈកម្ម-ការទី៥ ប្រចាំខែមេសា ខែឧសភា និងលើកទិសដៅ



អនុវត្តន៍សកម្មភាពការងារបន្តរបស់គណៈកម្មការ

២-ពិនិត្យនិងកែសម្រួលផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៣

៣-បូកសរុបចំណូល-ចំណាយថវិកាប្រចាំខែមេសា ខែឧសភា ឆ្នាំ២០២៣ និង

៤-បញ្ហាផ្សេងៗ។



-នារសៀថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្ម-ការទី៥ព្រឹទ្ធសភា ដើម្បីត្រៀម៖

១-ខ្លឹមសារ និងកម្រងសំណួរ ដើម្បីជួបពិភាក្សាការងារ រវាងគណៈកម្មការទី៥ព្រឹទ្ធសភា ជាមួយនឹងនាយ-ប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិភ្នំពេញ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣

២-ខ្លឹមសារ និងកម្រងសំណួរ ដើម្បីជួបពិភាក្សាការងារ រវាងគណៈកម្មការទី៥ព្រឹទ្ធសភា ជាមួយនឹងនាយ-ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ភ្នំពេញ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ និង

៣-បញ្ហាផ្សេងៗ។

❋ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដូចខាងក្រោម៖

-នាថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី៦ ព្រឹទ្ធសភា ដើម្បីពិនិត្យត្រៀមផ្តល់យោបល់ក្នុងសម័យប្រជុំ





លើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤ លើ៖

១-សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។



-នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី៦ព្រឹទ្ធសភា ដើម្បីពិនិត្យត្រៀមផ្តល់យោបល់ក្នុងសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤ លើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

២-សេចក្តីព្រាងច្បាប់ស្តីពីវិធានដើមកំណើតទំនិញ។

❋ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន ហើយយល់ឃើញថា សេចក្តីព្រាងច្បាប់ខាងលើនេះអាចលើកយកមកពិនិត្យសិក្សា ហើយឱ្យយោបល់បាន។

-នារសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈ-កម្មការជួបជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ច-ព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន នៅវិមានព្រឹទ្ធ-សភា។

-នាល្ងាចថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេសព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សាហើយឱ្យយោបល់ជាលើកចុងក្រោយ លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្មអាស៊ាន។



-នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្ម-ការទី១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) បានប្រជុំ ដើម្បីពិនិត្យ ពិភាក្សា ដើម្បីត្រៀម៖

១-ឱ្យយោបល់លើសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ

២-ឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្ម-អាស៊ាន និង

៣-បញ្ហាផ្សេងៗ។

-នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្ម-ការទី៩ព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី វិធានដើមកំណើតទំនិញ ហើយយល់ឃើញថា សេចក្តីព្រាងច្បាប់ខាងលើនេះអាចលើកយកមកពិនិត្យសិក្សា ហើយឱ្យយោបល់បាន។

-នារសៀលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ អន្តរគណៈ-



កម្មការជួបជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី វិធានដើមកំណើតទំនិញ នៅវិមានព្រឹទ្ធសភា។

-នាល្ងាចថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ នៅសាលប្រជុំពិសេសព្រឹទ្ធសភា ដើម្បីពិនិត្យ សិក្សាហើយឱ្យយោបល់ជាលើកចុងក្រោយ លើសេចក្ដីព្រាងច្បាប់ស្ដីពី វិធានដើមកំណើតទំនិញ។



-នារសៀលថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ នៅគណៈកម្មការទី១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) បានប្រជុំ ដើម្បីពិនិត្យ ពិភាក្សា ដើម្បីត្រៀម៖

១-ឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

២-ឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី វិធានដើមកំណើតទំនិញ និង

៣-បញ្ហាផ្សេងៗ។



❈នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យឆ្លងរបាយការណ៍ថវិកា និងរបាយការណ៍ស្ដីពី សកម្មភាពលទ្ធផលការងារប្រចាំខែមិថុនា និងលើកទិសដៅការងារបន្ត នៅគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមឃាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) នៅសាលប្រជុំពិសេស (VIP3) ព្រឹទ្ធសភា ដើម្បី៖

១-ផ្សព្វផ្សាយសេចក្ដីសម្រេច

២-ពិភាក្សាទៅលើកម្មវិធី

៣-បែងចែកតួនាទី និងភារកិច្ចផ្សេងៗ៕

## ការទទួលពាក្យបណ្ដឹង

❈នៅខែមិថុនា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី និងទទួលឯកសារជូនជ្រាបដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន១ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមមូលដ្ឋានទាំង៨

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីកាត់ឫសសីមា និងសម្ពោធសមិទ្ធផលនានា នៅក្នុងវត្តមហាកំផែងរាជកំពូលពេជ្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិកំពង់ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្មៀន ប្រធានភូមិទាំង៥ និងប្រធានមណ្ឌលសុខភាព ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងប្រគល់នូវឧបករណ៍តេស្តរហ័សកូវីដ-១៩ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនក្រុមប្រឹក្សាឃុំ និងមណ្ឌលសុខភាពចំនួន២កេសធំ មាន៦ប្រអប់តូច ស្មើនឹង ១.៥០០តេស្ត សម្រាប់ប្រើប្រាស់តាមតម្រូវការនៅមូលដ្ឋាន នៅមណ្ឌលសុខភាពគោលាប់ ឃុំគោលាប់ ស្រុកចិត្របុរី ខេត្តក្រចេះ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ទាំង៥ នៅសាលមហាស្រពខេត្តក្រចេះ នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងកម្មករ កម្មការិនី នៅតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីអំពី ការប្រកាសសមាសភាពគណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោតរាជធានីភ្នំពេញ និងផែនការត្រៀមបើកវគ្គបំប៉នមន្ត្រីការិយាល័យបោះឆ្នោតរបស់សង្កាត់ (CEC) មន្ត្រីចូលរួមក្នុងការិយាល័យបោះឆ្នោត (PSO)



និងភ្នាក់ងារសង្កេតការណ៍បោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ តាមបណ្តាខណ្ឌទាំង ១៤ នៅរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំ ដើម្បីពិភាក្សាអនុវត្តកម្មវិធីការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាពេលខាងមុខ ក្រោមអធិបតីភាពឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។



-ជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យគម្រប់៧ថ្ងៃ និង១០០ថ្ងៃ របស់ឧបាសក **ជា នៅ** នៅផ្ទះ១២៧E ផ្លូវលំ ភូមិតាងៅ សង្កាត់និរោធ ខណ្ឌ



ច្បារអំពៅ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ ២០២៣។



-ផ្តល់អង្ករជូនមន្ត្រី នៃលេខាធិការដ្ឋានអមគណៈកម្មការទី២ ព្រឹទ្ធសភា មន្ត្រី នៃលេខាធិការដ្ឋានអមគណៈកម្មការក្រមសីលធម៌ និងមន្ត្រី នៃការិយាល័យអមក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ស្ថិតក្នុងគេហដ្ឋាន សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករ និងចុះពិនិត្យដំណើរការរោងចក្រចំណីសត្វ ព្រមទាំងណែនាំពួកគាត់អំពីរបៀបដាំដំណាំដូងក្រអូប និងដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ទឹក ភ្លើង នៅលើផ្ទៃដី១៧២ ហិកតា ដើម្បីត្រៀមបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសកសិកម្ម រៀបចំសម្អាតដី ដើម្បីរៀបចំដាំកូនដើមដូងក្រអូបចំនួន១៨.០០០ដើម និងពិនិត្យមើលហេដ្ឋារចនាសម្ព័ន្ធផ្លូវ ប្រព័ន្ធរំដោះទឹកជំនន់ទឹកភ្លៀង នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យចម្ការដូងក្រអូប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ទទួលជួបលោក **ហាក់ ទិសាល** នាំយកត្រីគល់រាំង ចំនួន ៧២ក្បាល យកមកចិញ្ចឹមរក្សាទុកនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃព្រឹកទី៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន និងទំនប់ទឹក នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃព្រឹកទី១០ ខែមិថុនា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខលោកគ្រូអ្នកគ្រូ និងសិស្សសាលាអន្តជាតិអ៊ីអេសអិល ចំនួន២៨៩នាក់ អញ្ជើញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម និងកសិឧស្សាហកម្ម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ព្រមទាំងឧបត្ថម្ភកូនដើមឈើ រួមមាន៖ ត្របែកព្រៃ សាគូរ៉ា និង អូញម៉ូញ ចំនួន២០០ដើម ដើម្បីដាំនៅបរិវេណសាលា នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងនិមន្តព្រះសង្ឃ ប្រជាពលរដ្ឋ និងក្រុមការងារកសិកម្ម ចូលរួមដាំកូនដើមឈើផ្តល់ចំនួន១៥.៥៦២ដើម ដើម្បីចូលរួមថែរក្សាការពារបរិស្ថានជាមួយនឹងរាជរដ្ឋាភិបាល នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃព្រឹកទី១៥ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណេះសំណាល សួរសុខទុក្ខកម្មករកំពុងប្រមូលផលផ្លែទុរេន និងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃរសៀលទី១៥ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខកម្មករចម្ការកៅស៊ូ និងចុះពិនិត្យមើលរោងចក្រផលិតកៅស៊ូក្រែប នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាថ្ងៃរសៀលទី១៧ ខែមិថុនា ឆ្នាំ ២០២៣។



❈នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់សមាជិក សមាជិកា ក្រុមប្រឹក្សាឃុំ នៅសាលាស្រុកព្រះស្តេច ខេត្តព្រៃវែង។

❈នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន**



ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា និងឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបើកការដ្ឋានជួសជុលផ្លូវលេខ៣១២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកព្រះស្ដេច ខេត្តព្រៃវែង។

❈លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សាកសួរសុខទុក្ខ និងចែកអំណោយជូនប្រជាជនក្រីក្រចំនួន៣០០គ្រួសារ ទាំង១១ឃុំ ដោយក្នុងមួយគ្រួសារៗទទួលបាន៖ អង្ករ២០គីឡូក្រាម មីម៉ាម៉ា១កេស ទឹកស៊ីអ៊ីវ១យួរ ទឹកត្រី១យួរ ស្ករ-ស១កញ្ចប់ សារុង១ ក្រមា១ និងថវិកាមួយចំនួន ព្រមទាំងចែកជូនដល់សិស្សានុសិស្សចំនួន១០០នាក់ ដោយក្នុងម្នាក់ៗទទួលបាន៖ ខោអាវសិស្ស១សម្រាប់ និងថវិកាមួយចំនួន និងឧបត្ថម្ភដល់ក្រុមការងាររៀបចំពិធីនូវថវិកាមួយចំនួន នៅស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសាកសួរសុខទុក្ខលោក លោកស្រីសមាជិកក្រុមប្រឹក្សាស្រុក និងនាំយកជំនួយរបស់លោកជំទាវសាស្ត្រាចារ្យវេជ្ជបណ្ឌិត **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល នូវថ្នាំចំនួន៩មុខ រួមមាន៖ Amoxicillin ៦កំប៉ុង ParaCPE ៦កំប៉ុង AFD Multivitamin៦កំប៉ុង Chlorphenamine ៦កំប៉ុង Hyoscine Butylbromide ៦កំប៉ុង Sulfamethozazole ៦កំប៉ុង CO-Megaldrox ៦កំប៉ុង Acetamimophen ៤០០ដប Bromexine៦កំប៉ុងសម្រាប់បែងចែកជូនមន្ទីរពេទ្យបង្អែកស្រុកពញាឮ និងមណ្ឌលសុខភាពឃុំទាំង៩ និងឧបត្ថម្ភជូនអ្នកចូលរួមនូវអាវយឺត១៥ និងថវិកាមួយចំនួន នៅស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលថ្នាក់ដឹកនាំអង្គភាពសុខាភិបាលស្រុក និងតាមខ្នងផ្ទះប្រជាពលរដ្ឋ ព្រមទាំងជួបសួរសុខទុក្ខយុវជនកំព្រាឪពុកម្ដាយ៤នាក់ និងនាំយកជំនួយលោកជំទាវសាស្ត្រាចារ្យវេជ្ជបណ្ឌិត **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល នូវថ្នាំចំនួន៩មុខគឺ Amoxicillin ៦កំប៉ុង Para CPE ៦កំប៉ុង AFDmultivitamin ៦កំប៉ុង Chlorphenamine ៦កំប៉ុង Hyoscine Butylbromide ៦កំប៉ុង Sulfame thozazole៦កំប៉ុង CO-Megaldrox ៦កំប៉ុង Acetamimophen ៤០០ដប Bromexine ៦កំប៉ុង និងថវិកាមួយចំនួន ប្រគល់ជូនមន្ទីរពេទ្យបង្អែកស្រុក និង៩មណ្ឌលសុខភាពឃុំ ហើយប្រធានអង្គភាពនីមួយៗបានមកទទួលផ្ទាល់ជាមួយនឹងថវិកាមួយចំនួន។ ចំពោះយុវជនកំព្រាពិការទទួលបាននូវរទេះជនពិការ២គ្រឿង ខោអាវ៥ឈុត អង្ករ៥០គីឡូក្រាម ត្រីខ១យួរ ទឹកត្រីទឹកស៊ីអ៊ីវ២យួរ អំបិល១គីឡូក្រាម ប៊ីចេង១កញ្ចប់ ស្ករ-ស២គីឡូក្រាម នំធុង២ធុង ភេសជ្ជៈCocacola ១កេស សាប៊ូLux៨ដុំ និងថវិកាមួយចំនួន និងឧបត្ថម្ភថវិកាមួយចំនួនទៀតជូនមន្ត្រីឃុំ៦នាក់ នៅស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៩ និងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ងឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលបងប្អូនកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ។

❈នាថ្ងៃទី២៩ ខែឧសភា និងថ្ងៃទី៥ ថ្ងៃទី៧ ថ្ងៃទី១៥ ថ្ងៃទី



១៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្នោរ ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាសង្កាត់ និងស្មៀន ភូមិត្បែងមានជ័យ សង្កាត់ឪឡោក ខណ្ឌកំបូល សង្កាត់ឃ្មួញ ខណ្ឌសែនសុខ និងសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់ពីសភាពការណ៍ក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

❈នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចូលរួមពិធីបញ្ចុះខណ្ឌសីមាវត្តបុទុមព្រឹក្ស (ហៅវត្តពពេល) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៅឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

❈នាថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីស្ដាប់សំណូមពរ និងគោលការណ៍ចាំបាច់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ នៅស្រុកមេមត់ ស្រុកត្បូងឃ្មុំ និងក្រុងសួង ខេត្តត្បូងឃ្មុំ។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលតាមខ្នងផ្ទះប្រជាពលរដ្ឋរស់នៅឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នារសៀលថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។



-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ជួបសំណេះសំណាល និងប្រគល់ចង្ក្រានសន្សំសំចៃថាមពលចំនួន២.៨៧៨ ចង្ក្រាន ជូនប្រធានក្រុមប្រឹក្សាឃុំចំនួន៨ឃុំ ក្នុងស្រុកស៊ីធរកណ្ដាល និងប្រធានក្រុមប្រឹក្សាឃុំចំនួន១ឃុំ ក្នុងស្រុកពារាំង សម្រាប់យកចែកជូនប្រជាពលរដ្ឋក្នុងឃុំ នៃស្រុកទាំងពីរ នៅសាលាស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នារសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។



-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រកិត្តិយស ផ្នែកអភិវឌ្ឍន៍ជនបទ ពីសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ ជូនសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាកលវិទ្យាល័យជាស៊ីមកំចាយមារ ស្រុកកំចាយមារ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។




-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ជួបសំណេះសំណាល និងចែកចង្ក្រានសន្សំសំចៃថាមពលចំនួន៦៣៥ចង្ក្រាន ជូនប្រជាពលរដ្ឋនៅក្នុងឃុំរំលេច ចំនួន៣៦៤ចង្ក្រាន និងឃុំឫស្សីសាញ់ ចំនួន២៧១ចង្ក្រាន នៅស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលកម្មករ និយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិចាស់ ឃុំ

ព្រៃញាត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋចំនួន២៩៤នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ប្រជាពលរដ្ឋ អាជ្ញាធរ ភូមិ ឃុំ ទាំង២៩៤នាក់ មណ្ឌលសុខភាពឃុំត្រពាំងវែង និងចូលបច្ច័យបុណ្យសពប្រជាពលរដ្ឋចំនួន៧គ្រួសារ នៅឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋតាមខ្នងផ្ទះ ចំនួន៣ភូមិ គឺភូមិព្រៃទទឹង ភូមិតំណាកត្របែក និងភូមិត្រពាំងបាគូ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់បងប្អូនប្រជាពលរដ្ឋ នៅឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នារសៀលថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋតាមខ្នងផ្ទះ ចំនួន៣ភូមិ គឺភូមិក្បាលសេះ ភូមិគ្រាំងផ្ទៃ និងភូមិចារ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋនៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នារសៀលថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋតាមខ្នងផ្ទះ ចំនួន៣ភូមិគឺ ភូមិគោកព្រីង ភូមិគោកត្រប់ និងភូមិ



លៀក ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋ នៅឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋតាមខ្នងផ្ទះ ចំនួន២ភូមិ គឺភូមិតាឡឹក និងភូមិស្លែង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋ ក្នុងឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នារសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



❋នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលកម្មករ និយោជិត នៅរោងចក្រលីន វេនជី សាន់បូ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិជ័យជំនះ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅខេត្តតាកែវ នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ស្មៀននាយប៉ុស្ដិ៍រដ្ឋបាល និងប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានាក្នុងវត្តនវទីបនារាម (ហៅវត្តកោះពាមរាំង) ក្រោមអធិបតីភាពឯកឧត្ដមកិត្តិសេដ្ឋាបណ្ឌិត **ខាម ឃឿន** អនុប្រធានទី១រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ និងលើកទិសដៅការងារបន្តរបស់ឃុំឫស្សីស្រុក នៃស្រុកពាមជរ និងពិភាក្សាអំពីការងារសំខាន់ៗឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៧ នាពេលខាងមុខ នៅខេត្តព្រៃវែង នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា១ខ្នងមាន៣បន្ទប់ នៅសាលាបឋមសិក្សាកោះរកា ឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង ក្រោមអធិតីភាពឯកឧត្ដម **ស្មោង សារ៉ាត** ប្រធានក្រុមប្រឹក្សាខេត្តព្រៃវែង នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-នាំយកថ្នាំពេទ្យដែលជាអំណោយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ផ្ដល់ជូនមន្ទីរពេទ្យបង្អែក ស្រុកពាមជរ ខេត្តព្រៃវែង សម្រាប់ព្យាបាលជូនប្រជាពលរដ្ឋ នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ និងអង្គភាពភូមិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅវិទ្យាល័យរុក្ខគិរី ភូមិព្រៃអម្ពាន់ ឃុំស្ដុកប្រវឹក ស្រុករុក្ខគិរី ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ និងអង្គភាពភូមិក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិព្រែកតាច្រែង ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។



❈នារសៀលថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្ដម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្ដម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និវត្តជន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅបរិវេណវិទ្យាល័យស្រុករុក្ខគិរី ក្នុងស្រុករុក្ខគិរី ខេត្តបាត់ដំបង។

❈ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្ដម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្ដម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្ដម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជួបសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន សរុបចំនួន៣៤១២នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកសំឡូត ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមជួបសំណេះសំណាលមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យាសាលាខេត្ត និងមន្ត្រីសុខាភិបាល នៃរដ្ឋបាលខេត្ត សរុប



ចំនួន២.០៨៨នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាខេត្តបាត់ដំបង នារសៀលថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០២៣។



-ចូលរួមជួបសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន និងអតីតយុទ្ធជន សរុបចំនួន២.៦២៣នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

❋ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ កងកម្លាំងប្រដាប់អាវុធ និវត្តជន និងអតីតយុទ្ធជនមកពីស្រុកសំឡូត ស្រុកកំរៀង ស្រុកសំពៅលូន និងស្រុកភ្នំព្រឹកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅបរិវេណកសិដ្ឋានភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ កងកម្លាំងប្រដាប់អាវុធ និវត្តជន និងយោធិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកបវេល ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ កងកម្លាំងប្រដាប់អាវុធ និវត្តជន និងយោធិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកសង្កែ ខេត្តបាត់ដំបង នារសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមជួបសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន និងអតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ អង្គភាពភូមិស្រុកកោះក្រឡ សរុបចំនួន១១៩២នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្នុងបរិវេណ វត្តព្រះផុស ឃុំព្រះផុស ស្រុកកោះក្រឡ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០២៣។



-ចូលរួមក្នុងពិធីសំណេះសំណាលមន្ត្រីរាជការ ក្រុមប្រឹក្សាសង្កាត់ កងកម្លាំងប្រដាប់អាវុធ អតីតយុទ្ធជន លោកគ្រូ អ្នកគ្រូ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកមកពីក្រុងបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសុភមង្គល ខេត្តបាត់ដំបង នារសៀលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០២៣។



❋នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ជឹម លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីចែកសញ្ញាបត្រដល់សិស្សនិស្សិត ដែលទទួលជ័យលាភីជាង១.០០០នាក់ នៅសកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៅភូមិត្រពាំងឈ្លូស ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។



❋នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ជឹម លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា ១ខ្នងកម្ពស់២ជាន់ ស្មើនឹង១០បន្ទប់ទីចាត់ការ និងបណ្ណាល័យ ក្រោមធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលាបឋមសិក្សាព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

❋ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ជួបសំណេះ-សំណាលក្រុមប្រឹក្សាស្រុក អភិបាលស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនគបាលប៉ុស្តិ៍រដ្ឋបាល ដើម្បីឈ្វេងយល់ពីការអនុវត្តគោល-នយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់ឃុំក្នុងការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងគោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅឃុំចំនួន៤ គឺ ឃុំជាលា ឃុំច្បារអំពៅ ឃុំបាធាយ និងឃុំផ្អាវ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងក្នុង១ឃុំទទួលបានឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៧ប្រអប់តូច ជូនការិយាល័យស្រុកប្រតិបត្តិ និងជូនមន្ទីរពេទ្យបង្អែកស្រុកបាធាយ ចំនួន៣កេសធំ រដ្ឋបាលស្រុកបាធាយចំនួន១កេសធំ ជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ នៅស្រុកបាធាយ ខេត្តកំពង់-ចាម នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះសួរសុខទុក្ខ តាមផ្ទះបងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ៤ ព្រមទាំងឧបត្ថម្ភអង្ករ កន្សែងពោះគោ សាប៊ូ និងថវិកាមួយចំនួន នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានី-

ភ្នំពេញ នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីប្រជុំការងារព្រះពុទ្ធសាសនា ការងារពុទ្ធិកសិក្សា ត្រៀមលក្ខណៈកាន់ព្រះវស្សា និងផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចសង្ឃសន្និបាតមន្ត្រីសង្ឃរាជធានីភ្នំពេញ ឆ្នាំ២០២៣ នៅវត្តមង្គលសិរីគៀនឃ្លាំង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមប្រជុំជាមួយលោកប្រធានភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ដើម្បីស្តាប់របាយការណ៍ស្តីពី លទ្ធផលការងារខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៣ នៅខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីប្រជុំការងារព្រះពុទ្ធសាសនា ការងារពុទ្ធិកសិក្សា នៅវត្តនាគវ័ន្ត ខណ្ឌទួលគោក និងវត្តឧណ្ណាលោម ដើម្បីត្រៀមលក្ខណៈកាន់ព្រះវស្សា និងផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្តីសម្រេចសង្ឃសន្និបាតមន្ត្រីសង្ឃរាជធានីភ្នំពេញ ឆ្នាំ២០២៣ នៅខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសិតទៀនវស្សាសមាទានសីល និងនាំយកចង្ហាន់បិណ្ឌបាតប្រគេនព្រះសង្ឃចំនួន៣៣៦អង្គ ព្រមទាំងធ្វើ



បុណ្យចែកទានជូនប្រជាពលរដ្ឋ ក្នុងបរិវេណវត្តនាគវ័ន្ត ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❋នាព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្តាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលកម្មករ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅជាប់វត្តព្រៃស្ពឺ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

❋ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖




-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលបងប្អូនកម្មករនិយោជិត នៅសួនឧស្សាហកម្មខេមតុន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសួនឧស្សាហកម្មខេមតុន ភូមិផ្សារដែកលើ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលថ្នាក់ដឹកនាំ សមាជិក សមាជិកាមូលដ្ឋាន នៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវបេតុងអាម៉េមួយខ្សែប្រវែង១.៥៥៧ម៉ែត្រ ទទឹង៦ម៉ែត្រ មានកម្រាស់០.១៥

ម៉ែត្រ ក្នុងឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំដំណាក់អំពិល នៅស្រុកអង្គស្នួល ខេត្តកណ្តាល និងឧបត្ថម្ភថវិកាមួយចំនួន នារសៀលថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល និងសួរសុខទុក្ខចាស់ព្រឹទ្ធាចារ្យអាយុ ៩៩ឆ្នាំ គ្រួសារក្រីក្រ ព្រមទាំងចូលរួមរំលែកទុក្ខគ្រួសារ នៃសព និងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិត្រោក និងភូមិព្រះពន្លា ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិភាក្សាការងារថ្នាក់ដឹកនាំខេត្ត ស្រុក ក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងអ្នកពាក់ព័ន្ធមួយចំនួន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ នៅភូមិត្រពាំរុន ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងប្រជាពលរដ្ឋសរុបចំនួន១១៤នាក់ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ នៅភូមិត្រពាំងលាជ និងភូមិព្រីងជ្រុំ ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចុះត្រួតពិនិត្យបើកការដ្ឋានសាងសង់ផ្លូវបេតុង ដែលបន្តពីភូមិត្រោកទៅភូមិព្រះពន្លា ដែលមានប្រវែង៧០៥ម៉ែត្រ និងកម្រាស់០.១៥ម៉ែត្រ ព្រមទាំងជួបជាមួយព្រឹទ្ធាចារ្យ និងប្រជាពលរដ្ឋចាស់ជរា ក្នុងភូមិត្រោក ឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភាឆ្នាំ ២០២៣ និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្វាយរៀង នៅសាលប្រជុំខេត្តស្វាយរៀង នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាលនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយរៀង នាថ្ងៃទី២ ថ្ងៃទី៩ និងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ អនុប្រធានភូមិ និងអ្នកពាក់ព័ន្ធមួយចំនួន ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១១ ថ្ងៃទី១៦ និងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យស្រោចស្រពព្រះសុគន្ធវារីប្រគេនព្រះមុនីសត្ថាចារ្យកោសល្យ **កែវ ចន្ថា** ព្រះមេគណខេត្តកំពង់ស្ពឺ ព្រមទាំងនាំយកទេយ្យវត្ថុមួយចំនួន ដើម្បីវេរប្រគេនដល់ព្រះសង្ឃរួមមាន៖ អង្ករចំនួន២បាវ ទឹកបរិសុទ្ធចំនួន៥កេស ទឹកក្រូចចំនួន៥កេស ទឹកស៊ីអ៊ីវ១យួរ ទឹកត្រី១យួរ សាប៊ូលាងចានចំនួន៥លីត្រ ម្សៅសាប៊ូចំនួន៤គីឡូក្រាម ប្រេងឆាចំនួន២លីត្រ ស្ករ-សចំនួន៤គីឡូក្រាម អំបិលចំនួន៣គីឡូក្រាម ប៊ីចេងចំនួន ២គីឡូក្រាម ខ្ទឹមសចំនួន២គីឡូក្រាម។ល។ និងប្រគេនបច្ច័យមួយចំនួនដល់ព្រះសង្ឃចំនួន៤១អង្គ នៅវត្តដំណាក់ត្រាច ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ចំនួន២ឃុំគឺ ឃុំរលាំងគ្រើល និងឃុំរលាំងចក ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀម

រៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយមកចែកជូនដល់សមាជិក នៃអង្គពិធីក្នុងម្នាក់ៗទទួលបាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម ទឹកបរិសុទ្ធ១ដប និងថវិកាមួយចំនួន នៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលក្រុមប្រឹក្សាប្រឹក្សាឃុំ ភូមិ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយចែកជូនដល់សមាជិក នៃអង្គពិធីក្នុងម្នាក់ៗទទួលបាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម ទឹកបរិសុទ្ធ១ដប និងថវិកាមួយចំនួនដល់អាជ្ញាធរឃុំព្នាយ សម្រាប់ប្រើប្រាស់ នៅឃុំព្នាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីជួបសំណេះសំណាលកម្មករនិយោជិតមកពីរោងចក្រ សហគ្រាសនានា ចំនួន១៧.០០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ស្ថិតនៅរោងចក្រ វីងស្តារ ស៊ូ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវចំនួន៥ខ្សែ (ប្រវែងសរុប៩.៤៤៨ម៉ែត្រ ឆ្លងកាត់១២ភូមិ) ក្រោមអធិបតីភាពឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានគណៈកម្មការទី៧ រដ្ឋសភា នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបុណ្យខួបគម្រប់៣ឆ្នាំ របស់លោក **លឹម ណៃ** អតីតអភិបាលខេត្តព្រះសីហនុ និងចូលបច្ច័យបុណ្យមួយចំនួន នៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាលអាជ្ញាធរឃុំទាំង១៥ឃុំ របស់ស្រុកសំរោងទង ចំនួន៦១១នាក់ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់**




សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជួបសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន និងអតីតយុទ្ធជន លោកគ្រូ អ្នកគ្រូវិទ្យាល័យ អនុវិទ្យាល័យ ក្រុមប្រឹក្សាឃុំ ប្រធានភូមិ ក្នុងស្រុកឯកភ្នំ សរុបចំនួន១.៧០០នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅអតីតរោងចក្រក្រចៅជូនទាវ ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង។



❈នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០៣ លោកជំទាវ **គង់ សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សាវី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបញ្ចុះខណ្ឌ និងកាត់ឫសសីមាព្រះវិហារវត្តគិរីសិលា (ហៅវត្តភ្នំបាក់) គឺជាព្រះវិហារទី១៦ របស់ស្រុកកំពង់ត្រាច និងជាព្រះវិហារទី៧៤ របស់ខេត្តកំពត ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០ រដ្ឋសភា នៅភូមិដំណាក់កន្ទួត ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច ខេត្តកំពត។

❈លោកជំទាវ **គង់ សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលសន្និសីទបូកគោខេត្តកំពត នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលប្រជាពលរដ្ឋនៅស្រុកកំពង់ត្រាច ខេត្តកំពត នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **នាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ



ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកស្រូវពូជចែកជូនដល់បងប្អូនប្រជាពលរដ្ឋក្រីក្រ នៅភូមិអង្គជា ឃុំស្រែឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន២៦៩នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅឃុំព្រះពន្លា និងឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២៧ និងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន១.៩៣៥នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅភូមិត្រពាំងឈ្នាង ឃុំត្រពាំងស្តៅ ស្រុករមាសហែក និងសង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-នាំយកសម្ភារការិយាល័យមួយចំនួនទៅប្រគល់ជូនគណៈបញ្ជាការយោធាព្រំដែនខេត្តឡុងអាន រួមមាន៖ កុំព្យូទ័រមួយគ្រឿង ព្រីនធ័រមួយគ្រឿង សៀវភៅសរសេរ១.០០០ក្បាល និងប៊ិច៥០០ដើម ជូនគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ បឋមសិក្សាកន្ទួយរៃ នៅសង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៣០០០នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន២០០នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ចុះត្រួតពិនិត្យការងារលើកគ្រឹះផ្លូវថ្មីមួយខ្សែទៅកាន់ស្រែចម្ការ



ដើម្បីជួយសម្រួលដល់ប្រជាកសិករក្នុងការធ្វើដំណើរ ក៏ដូចជាការដឹកជញ្ជូនកសិផលនានា មានភាពងាយស្រួលទាំងរដូវវស្សា និងរដូវប្រាំង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់ការងារជួសជុលផ្លូវនៅភូមិដូនណូយ ឃុំទ្រាស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ និងប្រធានភូមិ ដើម្បីស្តាប់លទ្ធផល នៃវឌ្ឍនភាពការងារដែលបានអនុវត្តកន្លងមក និងការងារពង្រឹងសណ្តាប់ធ្នាប់ សន្តិសុខ-សង្គម ពិសេសការត្រៀមលក្ខណៈឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលប្រជុំសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពី ការជំរុញការអនុវត្តគម្រោងផលិតកម្មគ្រាប់ពូជស្រូវ នៃការនាំចេញអង្ករគុណភាពល្អ និងការបង្កើតសហគមន៍កសិកម្មក្នុងមូលដ្ឋាន ព្រមទាំងឧបត្ថម្ភវិទ្យុ-ទាក់ទងជូនប្រជាការពារភូមិពន្លៃចាស់ រៀបចំពិសាបាយសាមគ្គី និងថវិកាមួយចំនួន នៅវត្តបន្ទាយទូក ភូមិទ្រាស ឃុំទ្រាស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលលោកនាយក នាយករង លោកគ្រូ អ្នកគ្រូ សាលាបឋមសិក្សាប្រិយ៍ ឃុំទ្រាស វិទ្យាល័យផ្គាំ សាលាបឋមសិក្សាទាំងអស់ក្នុងឃុំផ្គាំ និងចុះត្រួតពិនិត្យប្រភពទឹក



អាងខ្វារកើត ឃុំរលួស ព្រមទាំងកាយប្រឡាយបង្ហូរទឹកមកកៀកជិតស្ទឹង បូមបញ្ចូលក្នុងស្ទឹងជូនប្រជាពលរដ្ឋប្រើប្រាស់ និងបន្តដំណើរទៅភូមិប្រីយ៍ ឃុំទ្រាស់ រៀបចំធ្វើលូជ្រុងបន្ថែមនៅចំហៀងលូចាស់ដែលមានស្រាប់២កន្លែង ដើម្បីរំដោះទឹកជន់លិចនៅរដូវវស្សា និងឧបត្ថម្ភថវិកាចូលរួមកសាងបល្ល័ង្កតម្កល់បរមរូបព្រះបាទជ័យវរ្ម័នទី៧ និងបានរៀបចំអាហារសាមគ្គី នៅស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៥ និងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។



-ចុះពិនិត្យតាមបណ្ដាភូមិ ដើម្បីពិនិត្យជាក់ស្ដែង និងការដោះស្រាយសំណូមពរចាំបាច់នានា ព្រមទាំងបន្តចុះភូមិ ពិនិត្យមើលផ្លូវកំពុងសាងសង់ (ភូមិអូរ) ពិនិត្យទីតាំងស្ពានថ្មដែលចាស់ទ្រុឌទ្រោម ភូមិយាងរៀង ពិនិត្យផ្លូវលំបាកមានប្រវែង១.៧០០ម៉ែត្រ ភូមិម៉ៅ ពិនិត្យផ្លូវលំបាកមានប្រវែង១.៦០០ម៉ែត្រ និងភូមិតាគល់ ក្នុងឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។



-ដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងបន្តដំណើរចុះជួបសំណេះសំណាល សួរសុខទុក្ខលោកនាយកលោកគ្រូ អ្នកគ្រូ និងសាលាបឋមសិក្សាសំរោង ព្រមទាំងឧបត្ថម្ភសារុង និងថវិកាមួយចំនួនសម្រាប់ដំណើរការជួសជុលដំបូលសាលា ដាំដើមផ្ទង់ លួសបន្លាធ្វើរបង និងបានពិនិត្យផ្លូវត្រូវជួសជុល នៅភូមិសំរោង ឃុំស្វាយចេក ឃុំទ្រាស់ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ និងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលគ្រិស្តបរិស័ទចំនួន១.៥០០នាក់ ប្រជាពលរដ្ឋចំនួន១.៨០០នាក់ និងសម្ពោធសមិទ្ធផលនានាៗ ព្រមទាំងឧបត្ថម្ភសារុង ថវិកាមួយចំនួន និងពិសាអាហារសាមគ្គី នៅផ្សារគំរូថ្មី ស្រុកថ្មពួក ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅសាលាខេត្តបន្ទាយមានជ័យ ខេត្តបន្ទាយមានជ័យនាថ្ងៃទី១៧ និងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។



-នាំយកគ្រឿងចក្រកាយលូ ដើម្បីកាយស្ដារសម្អាតដីស្ទះក្នុងលូជាច្រើនឆ្នាំ ដែលរងនូវការលិចទឹកពេលភ្លៀង ហើយបានធ្វើឱ្យលូមានភាពល្អប្រសើដូចដើមវិញ និងត្រូវរៀបចំធ្វើអាងសម្រាប់ស្ដារដីចេញនៅពេលស្ទះក្រោយៗទៀត ព្រមទាំងបន្តជួបសំណេះ-សំណាលអាជីវករលក់ដូរ និងប្រជាពលរដ្ឋ ជុំវិញផ្សារស្វាយចេក នៅឃុំរលួស ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

❋លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំតាមដានវឌ្ឍនភាពការងារឈានឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ នារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីមីទ្ទិញអបអរសាទរខួបទី៧៤ ទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៣ ក្រោមអធិបតីភាពសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលយុវជន យុវនារី ភូមិ១ ភូមិ២ ភូមិ៣ ភូមិ៤ និងភូមិ៥ ចំនួន៤៥នាក់ និងនាំយកថវិកាមួយចំនួនជាថវិការបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីមីទិញអបអរសាទខួបទី៧៤ ទិវាកុមារអន្តរជាតិ ១មិថុនា ទិវាពិភពលោកប្រឆាំងកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០២៣ នៅសាលាបឋមសិក្សាក្តីចាស់ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងយុវជន យុវនារី ថ្នាក់រាជធានី ខណ្ឌ និងសង្កាត់ទូទាំងរាជធានីភ្នំពេញ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC) នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសជាផ្លូវការសមាគមឧកញ៉ាកម្ពុជា និងពិសាអាហារសាមគ្គីនៃមហាគ្រួសារឧកញ៉ា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅដីព្រៃមៀសែនជ័យសែនសុខ ខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមកិច្ចប្រជុំស្តីពី ការត្រួតពិនិត្យ លទ្ធផលការងារអនុវត្តកន្លងមក និងរៀបចំផែនការ ដើម្បីឱ្យក្រុមការងារបន្តចុះជួយប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន ក្នុងខណ្ឌបឹងកេងកងរាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីសំណេះសំណាលនិវត្តជន អតីតយុទ្ធជន អាចារ្យ គណៈកម្មការវត្ត អាជីវករ គ្រូបង្រៀន និងគ្រូពេទ្យ ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅស្រុកព្រះស្តេច ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អតីតយុទ្ធជន និវត្តជន គ្រូបង្រៀន និងគ្រូពេទ្យ ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅស្រុកពោធិ៍រៀង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន គ្រូពេទ្យ និវត្តជន អាចារ្យ និងគណៈកម្មការវត្ត ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅស្រុកកញ្ជ្រៀច ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ គ្រូបង្រៀន គ្រូពេទ្យ និវត្តជន អាចារ្យ និងគណៈកម្មការវត្ត ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅស្រុកកំចាយមារ ខេត្តព្រៃវែង នារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធសមិទ្ធិផលនានាក្នុងវត្តបឹងដោល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិបឹងដោល ឃុំបឹងដោល ស្រុកព្រះស្តេច ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីសំណេះសំណាលមន្ត្រីរាជការ កងកម្លាំងប្រដាប់-អាវុធ គ្រូបង្រៀន គ្រូពេទ្យ និវត្តជន អាចារ្យ និងគណៈកម្មការវត្ត និងអ្នកសង្កេតការណ៍ ស.ស.យ.ក. ដែលមានសមាជិកចូលរួមសរុបចំនួន៤.៩៩២នាក់ ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា នៅក្រុងព្រៃវែង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលភ្នាក់ងារសង្កេតការណ៍បោះ-ឆ្នោតទូទាំងខេត្តព្រៃវែង ដែលមានសមាជិកចូលរួមសរុបចំនួន ៣.៧៧៨នាក់ ក្រោមអធិបតីភាពឯកឧត្តម **ស សុខា** រដ្ឋលេខា-ធិការក្រសួងអប់រំ យុវជន និងកីឡា នៅក្រុងព្រៃវែង ខេត្តព្រៃវែង នារសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤ភូមិគឺ ភូមិជំពូ ភូមិជ្រោយផ្គង ភូមិត្រពាំងទា និងភូមិស្រឡួង ស្ថិតក្នុងឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន១០ភូមិគឺ ភូមិដើម-សំរោង ភូមិប្រឡាយ ភូមិសំស្នេរ ភូមិពើក ភូមិដំរីលទី១ ភូមិដំរីលទី២ ភូមិដំរីលទី៣ ភូមិដំរីលទី៤ ភូមិសង្កែ និងភូមិជ្រៃសុខុម ស្ថិតក្នុងឃុំដំរីល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃ២៧ ខែឧសភា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីប្រកាសកែសម្រួល និងតែងតាំងប្រធានក្រុមការងារចុះជួយស្រុកក្រូចឆ្មារ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូប-នីយកម្ម និងសំណង់ នៅសាលប្រជុំសាលាស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងពិធីប្រកាសកែសម្រួល និងតែងតាំងប្រធានក្រុមការងារចុះជួយក្រុងសួង ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ នៅសាលប្រជុំសាលាក្រុងសួង ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋមកពីភូមិចំនួន៥ ស្ថិតក្នុងឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤ភូមិគឺ ភូមិទួល ភូមិយាកត្បូង ភូមិយាងជើង និងភូមិខ្ទប់ដំរីជើង ស្ថិតក្នុងវត្តដំរិល ឃុំដំរិល ព្រមទាំងជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំគងជ័យ ស្ថិតក្នុងវត្តស្រែស្ដៅ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលប្រជាពលរដ្ឋមកពីភូមិចំនួន៤គឺ ភូមិស្វាយមីង ភូមិពោធិ៍ស្វាយមីង ភូមិលេខ៤លិច ភូមិមាសស្នេហ៍ និងភូមិព្រៃស្រឡៅ ចំនួន៣៥០នាក់ ស្ថិតក្នុងវត្តស្វាយមីង ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលប្រជាពលរដ្ឋមកពីភូមិចំនួន៤គឺ ភូមិស្វាយតាឡុក ភូមិស្វាយរលួស ភូមិទួលតាលាប់ និងភូមិមិត្តរ៉ាច នៅសាលាឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤ភូមិគឺ ភូមិចក ភូមិប្រាសាទ ភូមិជ្រុល និងភូមិព្រីង នៅឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារខែមិថុនា ឆ្នាំ២០២៣ និងលើកទិសដៅបន្តរបស់ក្រុមការងារចុះជួយស្រុកអូររាំងឪ នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរភូមិ ឃុំ និងប្រជា-ពលរដ្ឋមកពីស្រុកអូររាំងឪចំនួន៦.៣៥០នាក់ នៅវិទ្យាល័យហ៊ុន សែន អូររាំងឪ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៤១៣នាក់ នៅសាលប្រជុំសាលាស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី ចណ្ណាថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រុមហ៊ុន ឡីក្រោន ស៊ូ អ៊ិនជាសស្ទ្រី ស្រុកជើងព្រៃ ខេត្តកំពង់ចាម។




❈នាព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២ ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី ចណ្ណាថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ នាយនគរបាលប៉ុស្ដិ៍រដ្ឋបាលឃុំ ស្មៀន និងប្រធានភូមិទាំង១០ នៃឃុំត្រពាំងគរ ដើម្បីឈ្វេងយល់អំពីការអនុវត្តការងារក្នុងមូលដ្ឋានឃុំត្រពាំងគរ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសពចំនួន៤គ្រួសារ ស្ដ្រីសម្រាលកូន១០នាក់ ប្រជាពលរដ្ឋដែលរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ សមាជិកក្នុងអង្គប្រជុំ និងស៊ីម៉ងត៍ចំនួន៣តោនជូនប៉ុស្ដិ៍នគរបាលដែលកំពុងជួសជុល និងសាងសង់ នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ូង សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សាលាធម្មសភា និងសមិទ្ធផលផ្សេងៗ ក្នុងវត្តសាមគ្គីរតនារាម (ហៅវត្តសំរោង) ក្រោមអធិបតីភាពឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល នៅឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សម្ដេចឧត្តមទេពញាណ **ហ៊ុន ណេង** ចំនួន៥៧នាក់ ពិនិត្យព្យាបាល និងផ្ដល់ថ្នាំជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃចំនួន៥០០នាក់ នៅឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋចំនួន៧០៦នាក់ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួននៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ស្មៀន នគរបាលប៉ុស្ដិ៍រដ្ឋបាល និងមណ្ឌលសុខភាព ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។

-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសម្ដេចឧត្តមទេពញាណ **ហ៊ុន ណេង** ចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋឥតគិតថ្លៃចំនួន៥០៩នាក់ និងឧបត្ថម្ភថវិកាមួយចំនួនដល់ក្រុមគ្រូពេទ្យ នៅឃុំអារក្សត្នោត ព្រមទាំងជួបសំណេះសំណាលលោកគ្រូ អ្នកគ្រូចំនួន៨១៧នាក់ និងឧបត្ថម្ភថវិកាមួយចំនួន នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋ ព្រមទាំងនាំយកឧបករណ៍តេស្ដរហ័សចំនួន៧ប្រអប់តូច និងឧបត្ថម្ភថវិកាមួយចំនួន នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីកាត់ឫសសីមាព្រះវិហារវត្តអង្គមន្ត្រីក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តអង្គទេព ភូមិអង្គរជ្ជួល ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ និងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិដូងតោក ឃុំត្រើយកោះ ក្រុងកំពត ខេត្តកំពត នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិព្រៃថ្នង ឃុំព្រៃថ្នង ខេត្តកំពត នារសៀលថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលប្រជាពលរដ្ឋ ក្រោមធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសាលសន្និសីទបូកគោ ខេត្តកំពត នាព្រឹក

ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខអ្នកជំងឺដែលជួបគ្រោះ-ថ្នាក់ចរាចរណ៍ កំពុងសម្រាកព្យាបាលនៅគេហដ្ឋាន ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ជូនដំណើរប្រជាពលរដ្ឋទៅធ្វើបុណ្យហាជី (ធម្មយាត្រា) ចំនួន៨៥នាក់ នៅប្រទេសអារ៉ាប់រួម នៅអាកាសយានដ្ឋានអន្តរ-ជាតិ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនដល់គណៈកម្មការព្រះវិហារ សម្រាប់ចាក់ដីទីធ្លាខាងមុខព្រះវិហារ នៅភូមិតាដិប សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត នារសៀលថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋចាស់ជរា ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់-ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❃ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធ-សភាបានអញ្ជើញ៖



-ជួបសំណេះសំណាលប្រជាពលរដ្ឋចំនួន៥០គ្រួសារ នៅស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❃លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាគណៈអធិបតីក្នុងពិធីពុទ្ធាភិសេក និងបញ្ចុះខ័ណ្ឌ-សីមាវត្តមុនីរង្សី (ហៅវត្តថ្មី) ក្រោមអធិបតីភាពឯកឧត្តមនាយ-ឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកង-យោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅវត្តមុនីរង្សី ភូមិស្នោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ នាយនគរបាលប៉ុស្តិ៍ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ព្រមទាំងឧបត្ថម្ភសម្ភារ និងថវិកាមួយចំនួនសម្រាប់សមា-ជិកចូលរួម និងជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកសម្ភារៈមួយចំនួនជូនលោកពូអតីតប្រធានឃុំ ដែលកំពុងមានជំងឺសម្រាកព្យាបាលនៅគេហដ្ឋានរួមមាន៖ អង្ករ៥០គីឡូក្រាម ទឹកដោះគោឆៅ២យួរ ស្ករ-ស១គីឡូក្រាម ត្រីខ២យួរ និងថវិកាមួយចំនួន នៅឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយខេត្តកំពង់ធំ នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីបុណ្យផ្កាមហាសាមគ្គី និងជួបសួរសុខទុក្ខសំណេះសំណាលលោកយាយ លោកតា បងប្អូន ប្រជាពលរដ្ឋនៅវត្តឥន្ទកុមារ ភូមិឥន្ទកុមារ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។

-ជាអធិបតីក្នុងពិធីបើកការដ្ឋានជួសជុលផ្លូវក្រាលក្រួសក្រហម ១ខ្សែ ប្រវែង៦.០០០ម៉ែត្រ ចាប់ពីភូមិថ្នល់បែក ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ តភ្ជាប់ទៅក្នុងភូមិទៀមចាស់ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

❃នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញប្រជុំជាមួយនឹងប្រធានក្រុមការងារចុះជួយសង្កាត់ស្នោរ ខណ្ឌកំបូល រាជ-ធានីភ្នំពេញ ព្រមទាំងជួបសំណេះសំណាលបងប្អូនប្រជាពលរដ្ឋចំនួន២ភូមិ គឺភូមិរំដួលជើង និងភូមិរំដួលត្បូង និងឧបត្ថម្ភដល់

ក្រុមការងារនូវថវិកាមួយចំនួនជូនក្រុមការងារសង្កាត់ ដើម្បីចូលរួមចំណែកជួយដល់បងប្អូនប្រជាពលរដ្ឋ។

❈ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅខេត្តតាកែវ នាថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅឃុំសិង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី៥ និងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋនៅភូមិវែង និងភូមិត្រពាំងគី ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ សរុបចំនួន៩៤២នាក់ និងឧបត្ថម្ភថវិកាមួយចំនួនសម្រាប់អ្នកធ្វើដំណើរ នៅឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ នាថ្ងៃទី១៧ និងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **លួន ណាំ** បានទទួលមរណភាព នៅគេហដ្ឋាន ភូមិពោធិ៍បន្ទាយជ័យ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី និងជាអនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីស្តាប់របាយការណ៍ប្រចាំខែឧសភា ឆ្នាំ២០២៣ និងទិសដៅបន្តខែមិថុនា ព្រមទាំងការងារត្រៀមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ នៅស្រុកអន្លង់វែង ក្រុងសំរោង និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ព្រមទាំង នាថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាអធិបតីក្នុងពិធីប្រកាសស្តីពី ការកែសម្រួលឡើង



វិញក្រុមការងារ ដើម្បីជំរុញអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ឱ្យទទួលបានជោគជ័យ ស្ថិតនៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣។




-ចូលរួមពិធីសម្ពោធវិហារឥស្លាម អាល់រ៉ស់ម៉ាស់ និងសមិទ្ធផលនានា ក្រោមធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិអូរតានេល ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។




-ជួបសំណេះសំណាលមន្ត្រីការិយាល័យអប់រំស្រុក លោកគ្រូអ្នកគ្រូវិទ្យាល័យ សាលាមត្តេយ្យ សាលាបឋម ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈសហគម ព្រមទាំងឧបត្ថម្ភកន្សែងពោះគោ និងថវិកាមួយចំនួន នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣។

-ប្រជុំជាមួយក្រុមប្រឹក្សាឃុំ ដើម្បីត្រួតពិនិត្យផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ និងចុះសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះទូទាំងឃុំព្រៃគ្រី ចំនួន២២៨៩គ្រួសារ ព្រមទាំងនាំយកអំណោយរបស់សម្តេចចៅហ្វាវាំងវររៀងជ័យអធិបតីស្រឹង្គារ **គង់ សំអុល** ចែកជូនបងប្អូនប្រជាពលរដ្ឋ រួមមាន៖ សារុង និងថវិកាមួយចំនួន នៅ



ឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលថ្នាក់ដឹកនាំ សមាជិក សមាជិកាក្នុងមូលដ្ឋានឃុំពងទឹក និងឧបត្ថម្ភជូនក្នុងម្នាក់ៗទទួលបានក្រមា១ នៅឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលថ្នាក់ដឹកនាំ សមាជិក សមាជិកាក្នុងមូលដ្ឋានឃុំអង្កោល និងឧបត្ថម្ភជូនក្នុងម្នាក់ៗទទួលបានក្រមា១ នៅឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលថ្នាក់ដឹកនាំ សមាជិក សមាជិកាក្នុងមូលដ្ឋានសង្កាត់កែប និងឧបត្ថម្ភជូនក្នុងម្នាក់ៗទទួលបានក្រមា១ នៅសង្កាត់កែប ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី៤ខែមិថុនា ឆ្នាំ២០២៣។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបការងារសម្រាប់ការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិនិត្យវឌ្ឍនភាព នៃការសាងសង់អគារសិក្សាមួយខ្នង នៅភូមិពោធិ៍ព្រឹក្សកើត ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលថ្នាក់ដឹកនាំ សមាជិក សមាជិកាក្នុងមូលដ្ឋានមកពី១១ភូមិ ក្នុងឃុំដូនតី និងបានឧបត្ថម្ភក្រមាមួយចំនួនជូនសមាជិកដែលបានចូលរួម នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក សមាជិកាមូលដ្ឋានមកពី៦ភូមិក្នុងឃុំដូនតីនិងឧបត្ថម្ភក្នុងម្នាក់ៗរួមមាន៖ ក្រមា ប៊ីចេង និងថវិកាមួយចំនួន នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី៩ ថ្ងៃទី១០ និងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។

❈នារសៀលថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ែម សាម៉ន** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខចៅសង្កាត់ ចៅសង្កាត់រង ក្រុមប្រឹក្សាសង្កាត់ ស្មៀន នាយនគរបាលប៉ុស្តិ៍រដ្ឋបាល ព្រមទាំងនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១កេសធំ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់ក្រុមប្រឹក្សាសង្កាត់ព្រះបាទ ទុកប្រើប្រាស់តាមត្រូវការ នៅសង្កាត់ព្រះបាទ ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។



❈នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ លោកជំទាវ **ស៊ី ចាន់ណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបើកការដ្ឋានលើកកម្រិត ជួសជុល និងថែទាំកំណាត់ផ្លូវជាតិលេខ២៣ ប្រវែង១៩.៨៣៣គីឡូម៉ែត្រ ចាប់ពីស្ពានកោះធំដល់ផ្លូវជាតិលេខ១៤ ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅភូមិលើកដែក ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្ដាល ខេត្តកណ្ដាល។

❈នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះ-សំណាលអាជ្ញាធរស្រុកអង្គរធំ ដើម្បីឈ្វេងយល់អំពី ការជួយដោះស្រាយការលំបាកក្នុងបញ្ហាសុខភាព និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ព្រះសង្ឃ និងប្រជាពលរដ្ឋទូទៅ នៅតាមភូមិ ឃុំ ព្រមទាំងនាំយកឧបករណ៍តេស្តកូវីដ-១៩ ចំនួន៣៥ប្រអប់តូចជូនដល់អាជ្ញាធរស្រុក និងឃុំចំនួន២៤ប្រអប់ នៅស្រុកអង្គរធំ ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលអាជ្ញាធរស្រុកប្រាសាទបាគង ដើម្បីឈ្វេងយល់អំពី ការត្រៀមរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅសាលាស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ ភូមិ សង្កាត់ ចំនួន១១៦នាក់ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងបានឧបត្ថម្ភដល់សមាជិក នៃអង្គ-ពិធីក្នុងម្នាក់ៗទទួលបាន៖ សារុង១ ថវិកាមួយចំនួន និងឧបត្ថម្ភថវិកាមួយចំនួនទៀតដល់អាជ្ញាធរឃុំអំពិលដើម្បីធ្វើការជួសជុលផ្លូវក្រាលគ្រួសក្រហមមួយខ្សែ (៦ម៉ែត្រ៧.០០០ម៉ែត្រ) នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❋នាល្ងាចថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១២រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកព្រឹត្តិការណ៍ប្រកួតកីឡាជនពិការអាស៊ី-អាគ្នេយ៍ (អាស៊ានប៉ារ៉ាហ្គេម លើកទី១២) ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❋នាល្ងាចថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១៤រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបិទព្រឹត្តិការណ៍ប្រកួតកីឡាជនពិការអាស៊ី-អាគ្នេយ៍ (អាស៊ានប៉ារ៉ាហ្គេម លើកទី១២) ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❋នាថ្ងៃទី៨ និងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។



❋នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧រូប បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយនឹងបងប្អូនកម្មករនិយោជិត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅសួនឧស្សាហកម្ម គ័នថេត ភូមិចម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ទទួលជួបព្រះតេជគុណ **គូ សុភាព** និមន្តទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងបានប្រគេនកូនដើមឈើធ្នង់ ដើមសាគូរ៉ា ដើមអូញម៉ូញ និងដើមត្របែកព្រៃ សរុបចំនួន៥០ដើម ដើម្បីដាំជាម្លប់សម្រាប់ប្រជាពលរដ្ឋនៅវត្តគល់ទទឹង នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣។

-ទទួលព្រះសង្ឃនិមន្តមកពីវត្តបឹងខ្នា ចំនួន៣៨អង្គមកទស្សនកិច្ច ព្រមទាំងពិនិត្យសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៣។

-ចូលរួមវេទិកាស្ដីពី ការការពារ និងអភិរក្សធនធានធម្មជាតិ ក្រោមប្រធានបទ “ការរៀបចំសហគមន៍តំបន់ការពារ



ធម្មជាតិនៅតំបន់អារ៉ែង” និង “ពង្រឹងសេវាកម្ម និងផលិត-ផលសហគមន៍ ដើម្បីជំរុញការនាំចេញនៅនឹងកន្លែង” ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅសាលប្រជុំ ម៉ុក ម៉ារ៉េត (ជាន់ទី៥) ទីស្ដីការក្រសួងបរិស្ថាន នាព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣។



-ទទួលជួបបណ្ឌិត Willam មកពីប្រទេសហូឡង់ ដើម្បីពិភាក្សាអំពី គម្រោងបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់-ជរា នៅក្នុងតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែន-ជ័យ នៅក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣។

-ទទួលសិស្សានុសិស្សចំនួន២០៣នាក់ មកពីសាលាអន្តរជាតិ ESL មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣។

❁ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានបេតុងខ្សែកាបឆ្លងកាត់ទន្លេសាប និងស្ពានអាកាសឫស្សីកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេ-ជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៣១



ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មីបាក់ខែង ជំហាន១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅតាមបណ្ដោយមហាវិថីឈ្នះ-ឈ្នះ ភូមិបាក់ខែងលើ សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣។

❁ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖



-ប្រគល់អំណោយដ៏ថ្លៃថ្លារបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ សម្រាប់ចែកជូនដល់ប្រជាពលរដ្ឋក្រីក្រនៅមូលដ្ឋាន រួមមាន៖ ឱសថ បរិក្ខារពេទ្យ សម្ភារប្រើប្រាស់ប្រចាំថ្ងៃ សម្ភារក្មេងលេង និង

សៀវភៅសរសេរ។ អំណោយទាំងអស់នេះទទួលបានពីមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នៅសាលសិក្ខាសាលាបណ្ណាល័យវិមានព្រឹទ្ធសភា នារសៀលថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣។



-ប្រគល់អំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ជូនដល់ក្រសួងមហាផ្ទៃ តាមរយៈឯកឧត្តមឧត្តមសេនីយ៍ឯក **គង់ ចាន់តារា** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ រួមមាន៖ ឱសថ និងបរិក្ខារពេទ្យ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ សម្ភារក្មេងលេង និងសៀវភៅសរសេរ អំណោយទាំងអស់នេះទទួលបានពីមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ នៅសាលសិក្ខាសាលាបណ្ណាល័យវិមានព្រឹទ្ធសភា នារសៀលថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣។

❈នាល្ងាចថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមអបអរសាទរទិវាប្រកាសឯករាជ្យជាតិលើកទី១២៥ របស់សាធារណរដ្ឋហ្វីលីពីន ដែលរៀបចំឡើងដោយស្ថានទូតសាធារណរដ្ឋហ្វីលីពីនប្រចាំកម្ពុជា នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ភ្នំពេញ។



❈នាព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលគោរពវិញ្ញាណក្ខន្ធសពលោកព្រឹទ្ធាចារ្យ **ចាយ ស៊ាខអ៊ី** ត្រូវជាឪពុកបង្កើតរបស់ឯកឧត្តម **ចាយ បូរិន** និងនាំយកថវិកាមួយចំនួនរបស់គណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីចូលបច្ច័យបុណ្យ នៅសង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។




❈នាថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ចណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមអមដំណើរជាមួយនឹងឯកឧត្តមនាយឧត្តមសេនីយ៍ បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក គោរពវិញ្ញាណក្ខន្ធសពឧកញ៉ាមហាសប្បុរសធម្មសេរីញាណ អគ្គមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ចាយ ស៊ាខអ៊ី** ដែលត្រូវជាឪពុកបង្កើតឯកឧត្តម **ចាយ បូរិន** អនុប្រធានគណៈកម្មការទី២រដ្ឋសភា នៅរាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីខួបអនុស្សាវរីយ៍លើកទី៤៦ ទិវានៃការចងចាំដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសាន៍ ប៉ុល ពត "២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៣" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការក្រសួងការពារជាតិ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។

❈នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣ លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបាន អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសហគមន៍ អេកូសេដ្ឋកិច្ចកម្ពុជា នៅខណ្ឌកំបូល រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបាន អញ្ជើញចូលរួមពិធីបិទសិក្ខាសាលាស្ដីពី កិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជា ឆ្នាំ២០២៣ នៅទីស្ដីការក្រសួងធម្មការ និងសាសនា៕

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈ចាប់ពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្ដម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្ដម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមវេទិកាថ្នាក់ដឹកនាំអាស៊ាន-កូរ៉េ (ASEAN-Korea Leader Forum) នៅកោះជេជូ នៃសាធារណរដ្ឋកូរ៉េ។



❈ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ បានអញ្ជើញចូលរួមសន្និសីទសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិក ស្ដីពី បរិស្ថាន និងការអភិវឌ្ឍ (APPCED) លើកទី២០ ក្រោមប្រធានបទ “យុទ្ធសាស្ត្រស្ដីពី ការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍បៃតង នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ”។



❈ចាប់ពីថ្ងៃទី២៨ ខែឧសភា ដល់ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៦ នៃក្រុមប្រឹក្សាពិគ្រោះយោបល់អាយប៉ាស្ដីពីគ្រឿងញៀន (The 6th AIPA Advisory Council on Dangerous Drug/ The 6th AIPA-CODD) ក្រោមប្រធានបទការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្នដើម្បីអាស៊ានគ្មានគ្រឿងញៀន នៅទីក្រុងបូហ្គ័រ ប្រទេសឥណ្ឌូណេស៊ី។



❈ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ាន់ ឈឿន** បានអញ្ជើញចូលរួមសិក្ខាសាលាសមាជិកសភាស្ដីពី “អភិបាលកិច្ចតាមប្រព័ន្ធឌីជីថល និងការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណែត” នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងកំណត់ទិសដៅការងារខែមិថុនា ឆ្នាំ២០២៣




*ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អ៊ុំ សារឹទ្ធ ឯកឧត្តម លីម ប៊ុនហុក*

នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារសម្រាប់ខែមិថុនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែឧសភាថា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានបន្តផ្តោតការយកចិត្តទុកលើការផ្តល់សេវាលើមុខងារទាំង៥របស់ព្រឹទ្ធសភា ដោយបានយកចិត្តទុកដាក់ជាអាទិភាពក្នុងការផ្តល់សេវាលើមុខងារតំណាង ដែលជាកិច្ចការចាំបាច់របស់សមាជិក សមាជិកាព្រឹទ្ធសភាចុះបំពេញការងារតាមមូលដ្ឋាន ក្នុងបរិបទឆ្ពោះទៅកាន់ការបោះឆ្នោតសកល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធ-





*អ្នកចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារខែមិថុនា ឆ្នាំ២០២៣*



*អ្នកចូលរួមប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែឧសភា និងលើកទិសដៅខែមិថុនា ឆ្នាំ២០២៣*

សភាបានរៀបចំ និងចាត់ចែងជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយនឹងគណៈប្រតិភូអន្តរ-ជាតិ ជាពិសេសជំនួបសវនាការជាមួយនឹងប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងប្រធានរដ្ឋសភានេប៉ាល់ ដើម្បីពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការតាមរយៈការទូតសភា។

ក្នុងខែឧសភានេះដែរ ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏ដូចប្រជាជនកម្ពុជាទាំងក្នុង និងក្រៅប្រទេស បានចូលរួមអប-អរសាទរជាមួយនឹងរាជរដ្ឋាភិបាលក្នុងការរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ ប្រកបដោយក្ដីសប្បាយរីករាយ និងភាពជោគជ័យដ៏ត្រចះត្រចង់ ដែលបានលើកស្ទួយកេរ្តិ៍ឈ្មោះ កិត្តិយស និងកិត្យានុភាពកម្ពុជា លើឆាកអន្តរជាតិ។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា សម្រាប់ខែមិថុនាខាងមុខនេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវត្រៀមសព្វសារពើសម្រាប់ការងារខាងមុខ គឺជារឿងអាទិភាពដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ ត្រូវតែខិតខំជាអតិបរមា ដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណសម្បត្តិសព្វយ៉ាង ទាំងទីកន្លែងធ្វើការ ធនធានសម្ភារៈ បរិក្ខារ បច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុមានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំបានទាន់ពេលវេលា ដូចការគ្រោងទុក ព្រមទាំងបន្តផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា លើមុខងារទាំង៥របស់ព្រឹទ្ធសភាឱ្យគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល កាន់តែល្អប្រសើរឡើងបន្ថែមទៀត។ ជាមួយគ្នានេះមន្ត្រីរាជការទាំងអស់ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានដាក់ចេញ និងបង្កើនការប្រុង-ប្រយ័ត្នជាងមុន ដើម្បីការពារកុំឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន៕

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គឹម សិទ្ធី)



*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅខែមិថុនា ឆ្នាំ២០២៣*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញប្រគល់-ទទួលកញ្ចប់សម្ភារៈសិក្សា សម្រាប់ចែកជូនសិស្សានុសិស្សក្នុងខណ្ឌជ្រោយចង្វារ



*ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញជាអធិបតីភាពក្នុងពិធីប្រគល់-ទទួលកញ្ចប់សម្ភារៈសិក្សាសម្រាប់ចែកជូនសិស្សានុសិស្សក្នុងខណ្ឌជ្រោយចង្វារ*

អំណោយជាសម្ភារៈសិក្សា (កញ្ចប់ផែនដា) ដែលគិតជាថវិកាប្រមាណជាង ២៧ម៉ឺនដុល្លារអាមេរិក ដែលជាជំនួយរបស់មូលនិធិចិនដើម្បីអភិវឌ្ឍជនបទ ត្រូវបានរៀបចំពិធីប្រគល់-ទទួល ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងលោក WANG HAOYU តំណាងមូលនិធិចិន ដើម្បីអភិវឌ្ឍជនបទ នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ នៅសាលាបឋមសិក្សាជ្រោយចង្វារ សម្រាប់ចែកជូនសិស្សានុសិស្សចំនួន៥.៣៦២នាក់ មកពីសាលាបឋមសិក្សាចំនួន១១ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ក្នុងឱកាសនោះ លោក WANG HAOYU តំណាងមូលនិធិចិន ដើម្បីអភិវឌ្ឍជនបទ បានជម្រាបជូនអង្គពិធីថា



*លោក WANG HAOYU អញ្ជើញថ្លែងសុន្ទរកថា*

សម្ភារៈសិក្សា (កញ្ចប់ផែនដា) នេះ គឺជាទឹកចិត្តដ៏សប្បុរសរបស់ប្រជាជនចិន ដើម្បីចូលរួមចំណែកលើកកម្ពស់ការសិក្សារបស់ក្មួយៗដែលជាសិស្សានុសិស្ស ក្នុងនាមជាអ្នកស្នង និងការចូលរួមអភិវឌ្ឍប្រទេសនាពេលខាងមុខ។

លោក WANG HAOYU បានបញ្ជាក់អំពីបុព្វហេតុដែលនាំឱ្យមានការយកកញ្ចប់ផែនដា ច្រើនជាង១,១៥លានចែកទៅកាន់១៤ប្រទេសនៅអាស៊ី និងអាហ្វ្រិក។ ហើយនេះជាលើកទីប្រាំពីរហើយ ដែលគម្រោងកញ្ចប់ផែនដាបានមកដល់ព្រះរាជាណាចក្រកម្ពុជា។ រហូតមកដល់ពេលនេះ កញ្ចប់ផែនដាចំនួន១៧ម៉ឺនកញ្ចប់ ត្រូវបានចែកជូននៅតាមសាលាបឋមសិក្សានានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការជាប្រពៃណីរបស់រដ្ឋាភិបាល និងប្រជាជនចិន ដែលជានិច្ចកាលបានផ្តល់នូវជំនួយយ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាជនកម្ពុជា។ ជាក់ស្តែងដូចនាពេលនេះគឺបាននាំយកនូវសម្ភារៈសិក្សា ដែលជាអំណោយដ៏ថ្លៃថ្លារបស់មូលនិធិចិន ដើម្បីអភិវឌ្ឍជនបទ តាមរយៈវេទិកាសម្ព័ន្ធសង្គមស៊ីវិល នៃទីស្តីការគណៈរដ្ឋមន្ត្រី ជូនដល់ក្មួយៗសិស្សានុសិស្សសាលាបឋមសិក្សាទាំង១១ ក្នុងខណ្ឌជ្រោយចង្វារ។




*ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញថ្លែងសុន្ទរកថា*

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ការងារអប់រំក៏ជាកិច្ចការអាទិភាពមួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចផែនការអភិវឌ្ឍជំរុញឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ការបង្កើនធនធានមនុស្សឱ្យមានសក្តានុពលខ្ពស់ជារឿងមិនអាចមើលរំលងបានឡើយ។ ដើម្បីសំដៅដល់កិច្ចអភិវឌ្ឍប្រទេសប្រកបដោយចីរភាព កុមារគឺជាធនធានដ៏សំខាន់ដែលត្រូវតែមានការយកចិត្តទុកដាក់ទាំងសុខភាព ចំណីអាហារ ការស្លៀកពាក់ និងការរៀនសូត្រ។ សម្ភារៈសិក្សា និងរបស់ប្រើប្រាស់ នៃកញ្ចប់ផែនដាដែលត្រូវរៀបចំឡើង និងប្រគល់ជូនទៅកាន់កុមារដែលជាសិស្សានុសិស្សទាំងអស់នេះ គឺជាកញ្ចប់ នៃក្តីស្រឡាញ់ដែលជាការគិតគូរដោយប្រមុខរដ្ឋាភិបាល នៃប្រទេសទាំង-ពីរ(កម្ពុជា-ចិន) ជាពិសេសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តែងតែយកចិត្តទុកដាក់ដល់សុខុមាលភាពប្រជាជនកម្ពុជាទាំងអស់ ចូលរួមធ្វើការអភិវឌ្ឍមូលដ្ឋាន សំដៅដល់ការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍប្រទេសជាតិស្របតាមផែនការបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានរំលឹកអំពីទំនាក់-ទំនងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាកម្ពុជា-ចិន ត្រូវបានពង្រឹងពង្រីក និងកាន់តែស៊ីជម្រៅថែមទៀតរហូតឈានដល់កម្រិត “ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ”។ កិច្ចសហប្រតិបត្តិការក្នុងកិច្ចការអន្តរជាតិ និងក្នុងតំបន់រវាងប្រទេសទាំងពីរ កាន់តែមានភាពជិតស្និទ្ធពីមួយថ្ងៃទៅមួយថ្ងៃ ដោយឈរលើមតិឯកភាពរួមផ្អែកនយោបាយកម្រិតខ្ពស់ ភាគីទាំងពីរមានការយោគយល់គ្នា គោរពគ្នា និងផ្តល់ការគាំទ្រដល់គ្នា រួមគ្នាគាំពារស្ថានការណ៍ នៃទំនាក់ទំនងរវាងចិន និងកម្ពុជា ព្រម-ទាំងសុខសន្តិភាព ស្ថិរភាពក្នុងតំបន់។

ក្នុងឱកាសនោះដែរ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានផ្តាំផ្ញើក្មួយៗសិស្សានុសិស្សត្រូវខិតខំប្រឹងប្រែងរៀនសូត្រ ក្រេបយកចំណេះវិជ្ជា ដើម្បីក្លាយទៅជាបញ្ញាជន ជាសសរទ្រូងដ៏រឹងមាំ នៃប្រទេសជាតិនាថ្ងៃអនាគត ហើយធ្វើជាប្រជាជនសុចរិត មានស្មារតី និងឆន្ទៈបម្រើជាតិមាតុភូមិមិនប្រាសចាកពីច្បាប់ និងសង្គមជាតិ៕

(អត្ថបទ៖ គឹម សិទ្ធី រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចូលរួមក្នុងពិធីប្រគល់-ទទួលកញ្ចប់សម្ភារៈសិក្សា*

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលាស្តីពី ការតម្រង់ទិស និងផ្សព្វផ្សាយអាហារូបករណ៍ទៅបន្តការសិក្សានៅប្រទេសចិន



ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលា នៅវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ

នាព្រឹកថ្ងៃទី១៧ និងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលាស្តីពី ការតម្រង់ទិស និងផ្សព្វផ្សាយអាហារូបករណ៍ទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងសមាគមនិស្សិតកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន គាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ និងវិទ្យាល័យព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ថ្លែងក្នុងអង្គសិក្ខាសាលាឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាននាំយកនូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ពិសេសក្មួយៗសិស្សានុសិស្សទាំងអស់ ដែលកំពុងសិក្សានៅវិទ្យាល័យ ជា ស៊ីម ជ្រោយចង្វារ និងវិទ្យាល័យព្រែកលៀប។

ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល ក៏ដូចជាផ្នែកឯកជននានា នៃប្រទេសចិន ដែលបានផ្តល់អាហារូបករណ៍ និងជំនួយឧបត្ថម្ភផ្សេងៗដល់និស្សិតកម្ពុជាបានទៅបន្តការសិក្សានៅប្រទេសចិនតាមរយៈការទទួលបានអាហារូបករណ៍ដែលមានចាប់តាំងពីឆ្នាំ១៩៩៨ រហូតមកដល់បច្ចុប្បន្ន។ ចំណុចនេះអាចនិយាយបានថា ប្រសិនបើពុំមានជំនួយឧបត្ថម្ភរបស់ប្រទេសចិនលើការបណ្តុះបណ្តាលធនធានមនុស្សដល់កម្ពុជា ដែលមានចំនួនកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំនោះទេ ក៏ពុំមានការ





ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញថ្លែងក្នុងអង្គសិក្ខាសាលា



ទិដ្ឋភាពលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចូលរួមក្នុងអង្គពិធី



*ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញជាអធិបតីភាពក្នុងអង្គសិក្ខាសាលា នៅវិទ្យាល័យព្រែកលៀប*

ផ្សព្វផ្សាយឱកាសទៅបន្តការសិក្សានៅប្រទេសចិន ជូនក្មួយៗដូចពេលនេះ។ ជាក់ស្ដែង កន្លងមកក៏ដូចជាបច្ចុប្បន្ន មានមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បាន និងកំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅរដ្ឋធានីប៉េកាំង ទីក្រុងវូហាន និងខេត្តផ្សេងៗផងដែរ។

ឯកឧត្តមបានជំរុញ និងលើកទឹកចិត្តឱ្យក្មួយៗសិស្សានុសិស្សទាំងអស់ ខិតខំប្រឹងប្រែងរៀនសូត្រ ក្រេបយកចំណេះវិជ្ជាផ្នែកភាសាឱ្យបានច្រើន មានដូចជា៖ភាសាអង់គ្លេស ភាសាបារាំង ភាសាផ្សេងៗទៀត ជាពិសេសភាសាចិន ព្រោះបច្ចុប្បន្ននេះ មិនថាឱកាសការងារ ឬការសិក្សានោះទេ គឺទាមទារឱ្យចេះប្រើប្រាស់ភាសាចិន។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានបញ្ជាក់ថា ឆ្នាំ ២០២៣ គឺជាឆ្នាំអបអរសាទរទំនាក់ទំនងកម្ពុជា-ចិន និងរំឭកខួប៦៥ឆ្នាំ នៃចំណងការទូតរវាងកម្ពុជា-ចិន ដែលមានតាំងពីសម័យព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ បន្តរហូតមកដល់បច្ចុប្បន្ន ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងបន្តចំណងមិត្តភាពដែកថែបមួយនេះឱ្យកាន់តែរឹងមាំ និងកាន់តែស៊ីជម្រៅ ក្រោមកិច្ចសហប្រតិបត្តិការនានា ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាយើងឱ្យកាន់តែរីកចម្រើនលើគ្រប់វិស័យ។ និស្សិតកម្ពុជាទៅបន្តការសិក្សានៅប្រទេសចិន បច្ចុប្បន្ននេះមានចំនួនសរុបប្រមាណ ១.២០០នាក់ ដែលកំពុងសិក្សានៅជាង១០០សកលវិទ្យាល័យក្នុង២៧ខេត្ត-ក្រុងទូទាំងប្រទេសចិន ជាចំនួនច្រើនជាងគេ បើធៀបនឹងប្រទេសផ្សេងៗទៀត ដែលមាននិស្សិតកម្ពុជាកំពុងបន្តការសិក្សា។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានសម្ដែងនូវការគាំទ្រសមាគមនិស្សិតបន្តផ្សព្វផ្សាយព័ត៌មានអាហារូបករណ៍ឱ្យបានទូលំទូលាយថែមទៀត ដើម្បីឱ្យសិស្សនិស្សិតទាំងអស់ទាំងតាមបណ្ដាខេត្ត និងនៅរាជធានី ដែលមានបំណងទៅបន្តការសិក្សានៅប្រទេសចិន បានឈ្វេងយល់ឱ្យច្បាស់ពីអាហារូបករណ៍សិក្សានៅប្រទេសចិន ក៏ដូចជាឈ្វេងយល់អំពីការរៀបចំឯកសារមុនចេញទៅសិក្សា ការធ្វើដំណើរចេញទៅសិក្សា ការរស់នៅ ការសិក្សា និងបទពិសោធន៍ក្នុងពេលកំពុងសិក្សា និងក្រោយពេលបញ្ចប់ការសិក្សា។

(អត្ថបទ និងរូបភាព៖ វ៉ាន់ ពិសិដ្ឋ)





*ទិដ្ឋភាពសិស្សានុសិស្ស ចូលរួមក្នុងអង្គពិធី*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខដាច់ដោយឡែកពីគ្នា ជាមួយនឹងអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតា-សេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជ-ធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម LEE Kwang-jae អគ្គលេខាធិការរដ្ឋសភាកូរ៉េ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងអគ្គលេខាធិការដ្ឋាន នៃសភាទាំងពីរ ជាពិសេសការលើកកម្ពស់សមត្ថភាពមន្ត្រីលើផ្នែកស្រាវជ្រាវសភា និងស្រាវជ្រាវថវិកា (PBO) នៅខេត្តជេជូ នៃសាធារណរដ្ឋកូរ៉េ។




❈នារសៀលថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងឯកឧត្តម LEE Kwang-jae អគ្គ-លេខាធិការរដ្ឋសភាកូរ៉េ លោកជំទាវអគ្គលេខាធិការអាយប៉ា និងលោកជំទាវអគ្គលេខាធិការរងសភាហ្វីលីពីន នៅខេត្តជេជូ នៃសាធារណរដ្ឋកូរ៉េ។



❈នាថ្ងៃទី៥ ទី៦ ទី៧ និងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពី ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការស្នើសុំតែងតាំងមន្ត្រីរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរង ឯកឧត្តម លោកជំទាវ អគ្គ-នាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ និងអង្គភាពពាក់ព័ន្ធ។



❈នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយនឹងលោក Wang Haoyu តំណាងមូលនិធិចិន ដើម្បីអភិវឌ្ឍជនបទ នៅសាលប្រជុំពិសេសវិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំ ដើម្បីពិនិត្យលទ្ធផលប្រឡងប្តូរប្រភេទក្របខ័ណ្ឌ (ក) សម្រាប់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋាន ចំនួន១០នាក់ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម អគ្គលេខាធិការរង ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ និងអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញប្រគល់-ទទួលសម្ភារៈបណ្ណាល័យអេឡិចត្រូនិក និងសម្ភារៈសិក្សាអេឡិចត្រូនិក ជូនដល់នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណាល័យព្រឹទ្ធសភា ក្រោមការឧបត្ថម្ភគាំទ្រពីស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដាក់កូរោនផ្កាគោរពវិញ្ញាណក្ខន្ធសពលោក **ណោង ឃួយ** ឪពុកបង្កើតរបស់លោក **ណោង សក្ខដា** អនុប្រធាននាយកដ្ឋានរដ្ឋបាល នៅគេហដ្ឋានសព ផ្ទះលេខ១៧R ផ្លូវ៣៦៨ បុរីវិមានភ្នំពេញ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងអង្គភាពសន្តិសុខ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងមន្ត្រីបុគ្គលិកបម្រើការផ្នែកសេវាកម្ម និងផ្នែកដឹកជញ្ជូន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៧នាក់ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល២០២៤-២០២៦ របស់ព្រឹទ្ធសភា ព្រមទាំងការងារផ្សេងៗ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងសិក្ខាសាលាស្តីពី ការតម្រង់ទិស និងផ្សព្វផ្សាយអាហារូបករណ៍ទៅបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន នៅវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន កោះដាច់ ស្ថិតក្នុងភូមិល្វា សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី ក្រមសីលធម៌ អរិយធម៌ និងប្រពៃណីទំនៀមទម្លាប់ជាតិ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញធ្វើបាឋកថាស្តីពី ការប្រៀបធៀបរវាងប្រព័ន្ធបោះឆ្នោតនៅកម្ពុជា និងបារាំង ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **លីម ម៉ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពីធីពិនិត្យភ្នែក វាស់កាត់វ៉ែនតាដោយឥតគិតថ្លៃ ជូនមន្ត្រីរាជការ នៃអគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា ចំនួន៨០០នាក់ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានអញ្ជើញដាក់កូរោនផ្កាគោរពវិញ្ញាណក្ខន្ធសពលោក **អ៊ុន ខា** និវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជាសមាជិកសមាគមសង្គហៈ មូលដ្ឋាន នៃអគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា នៅគេហដ្ឋានសព ស្ថិតនៅសង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ គណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **សួន ពុធថាវី** អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ បានអញ្ជើញដាក់កូរោនផ្កាគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ឈុន កែវ** ម្ដាយក្មេករបស់លោក **តុន គន្ធ** ប្រធាននាយកដ្ឋានស្រាវជ្រាវច្បាប់ នៅគេហដ្ឋានសព ស្ថិតនៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្ដាល។



❈នាព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ឯកឧត្តម **លី រិទ្ធី** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងជាតំណាងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយជាសម្ភារៈសិក្សា (កញ្ចប់ផេនដា) ដែលជាជំនួយរបស់មូលនិធិចិន ដើម្បីអភិវឌ្ឍន៍ជនបទចែកជូនដល់សិស្សានុសិស្សចំនួន៥៨០នាក់ នៅសាលាបឋម-សិក្សាជ្រោយសាគូរ៉ា ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



❈នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណារ៉ា** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធ-សភា បានអញ្ជើញនាំយកព្រះរាជដង្វាយរបស់សម្ដេចវិបុល-សេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណា-ចក្រកម្ពុជា មានដូចជា៖ ស្បៀងសារអាហារចំនួន៣៥មុខ រួមជាមួយនឹងថវិកាចំនួន១ម៉ឺនដុល្លារអាមេរិក ថ្វាយសម្ដេចព្រះ-មហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងថវិកា ១.៥០០ដុល្លារអាមេរិក សម្រាប់ព្រះរាជបរិពារ៕




ព្រឹទ្ធសភា នីតិកាលទី ៤
សម័យប្រជុំលើកទី ១០